ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យ វ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់ អគ្គនាយកដ្ឋានពន្ធដារ
# THE PROCEDURE OF COLLECTING WITHHOLDING TAX FOR GENERAL DEPARTMENT OF TAXATION

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់ អគ្គនាយកដ្ឋានពន្ធដារ

THE PROCEDURE OF COLLECTING WITHHOLDING TAX FOR GENERAL DEPARTMENT OF TAXATION

គ្រូណែនាំ៖ យាង គឹមអៀង

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២**
**ប្រធានបទ៖ នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

យ៉ាង គឹមអៀង

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃនិងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ួ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី អង្គការក្រៅរដ្ឋាភិបាលក្តីឬ អ្នកប្រកបមុខរបរអាជីវកម្មតូចធំក្តី សុទ្ធតែត្រូវអនុវត្ត កិច្ចការគណនេយ្យពន្ធដារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យ ហិរញ្ញវត្ថុ ធនាគារនិង គណនេយ្យពន្ធ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្ត ការងារវិស័យពន្ធដារពីការចាប់ផ្តើមរៀបចំផែនការ ការចាត់នីតិវិធី ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារវិស័យពន្ធដារ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលពន្ធនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសខុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



ម៉ាប់ ស្រីម៉ាច
ID: B22/1406



យា ស៊ីធាន
ID: B22/1935



ឆន់ សាមឿន
ID: B22/038



ជួន តាំងហ៊ុន
ID: B22/251



ចាន់ និមល
ID: B22/1304

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំ សូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ឃាង គឹមអៀង** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យ វ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អំណះអំណាង**

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ម៉ាប់ ស្រីម៉ាច

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ពន្ធ មានលក្ខណៈបង្ខំដោយស្របច្បាប់ ហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលដៅប្រទេសនីមួយៗ។ ពន្ធ គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតកិច្ចរបស់គ្រប់សមាភាពដែលកំណត់ដោយច្បាប់។ ការបង់ពន្ធគឺជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ឬស្ថាប័នពាក់ព័ន្ធនានាដែលត្រូវបង់ជូនរដ្ឋដើម្បីរួមចំណែកការពារ និងអភិវឌ្ឍន៍មាតុភូមិ។

ជាក់ស្តែង ពន្ធមានច្រើនប្រភេទ ក្នុងនោះពន្ធកាត់ ជាប្រភេទពន្ធមួយប្រភេទក្នុងចំណោមពន្ធផ្សេងៗ និងជាប្រភេទពន្ធផ្ទាល់ដែលរដ្ឋតម្រូវឱ្យបង់ជាប្រចាំខែ ពីអ្នកផ្គត់ផ្គង់និវាសនជន និង អនិវាសនជន តាមរយៈអ្នកជាប់ពន្ធនិវាសនជនទៅលើការផ្គត់ផ្គង់មួយចំនួន។ រាល់ប្រតិបត្តិការទាំងឡាយណា មុននឹងធ្វើការទូទាត់ឱ្យទៅបុគ្គលនិវាសនជនជាសាច់ប្រាក់ ឬទូទាត់ជាវត្ថុ ត្រូវកាត់ទុកជាមុននូវប្រាក់ពន្ធ មិនថាប្រតិបត្តិការទូទាត់ចំណាយក្នុងស្រុក ឬក្រៅស្រុកនោះទេ ត្រូវធ្វើការកាត់ទុក និងត្រូវបង់ពន្ធតាមអត្រាដែលរដ្ឋបានកំណត់ ។

*និវាសជនមានដូចជា

-ការបំពេញសេវានានា និងសួយសារចំពោះទ្រព្យអរូបី ក្នុងធនធានរ៉ែ

-ការបង់ការប្រាក់ទៅឱ្យអ្នកជាប់ពន្ធមិនមែនជាធនាគារ

-ការបង់ប្រាក់ឱ្យទៅអ្នកជាប់ពន្ធ ដែលមានគណនីសន្សំមានកាលកំណត់

-ការបង់ប្រាក់ឱ្យទៅអ្នកជាប់ពន្ធ ដែលមានគណនីសន្សំគ្មានកាលកំណត់

-ការបង់ថ្លៃឈ្នួលចលនទ្រព្យ និងអចលទ្រព្យ

*អនិវាសនជនមានដូចជា

ការទូទាត់ទាំងឡាយខាងក្រោមដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឲ្យទៅអនិវាសនជនដោយអ្នកជាប់ពន្ធអនិវាសនជនដែលប្រកបអាជីវកម្មត្រូវជាប់ពន្ធកាត់ទុក ។

-ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

-ការប្រាក់

-សួយសារបានមកពីទ្រព្យសកម្មអរូបីដែលបានទូទាត់ទៅឲ្យអនិវាសនជន

-សួយសារបានមកពីភាគកម្មនៅក្នុងធនធានរ៉ែប្រេងកាត ឬឧស្ម័នធម្មជាតិ។ សួយសារនេះសំដៅដល់អត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុដែលទទួលបានទាក់ទិននឹងភាគកម្មទាំងនេះ ក្រៅពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធានទាំងនេះនិងភាគលាភ

-ថ្លៃឈ្នួលទូទាត់ឲ្យទៅអនិវាសនជន

-ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសជន

-បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ចំពោះហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា។

ការខកខានមិនបានបំពេញកាតព្វកិច្ចកាត់ទុក ឬ មិនបានបង់ពន្ធកាត់ទុកឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាទេនោះ អ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុកនឹងត្រូវទទួលខុសត្រូវចំពោះប្រាក់ដែលមិនបានកាត់ទុកនោះព្រមទាំងត្រូវទទួលទោសទណ្ឌផ្សេងៗ ដូចមានបញ្ញត្តិក្នុងច្បាប់ស្តីពីសារពើពន្ធផងដែរ ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្ដីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្ដីផ្ដើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីក្នុងការប្រមូលពន្ធកាត់ទុកយ៉ាងដូចម្ដេច?
២.តើការប្រមូលពន្ធកាត់ទុកបានផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ និងមានផលប៉ះពាល់អ្វីខ្លះដល់អ្នកជាប់ពន្ធ?
១.៣ គោលបំណងនៃការស្រាវជ្រាវ
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៥.១ បកស្រាយតាមសំណួរទី១ ........ ៣
១.៥.២ បកស្រាយតាមសំណួរទី២ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី២
## នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់ពន្ធដារ


២.១ លក្ខណៈទូទៅនៃពន្ធ ........ ៥
២.១.១ និយមន័យរបស់ពន្ធ ........ ៥
២.១.២ ប្រវត្តិនៃពន្ធ ........ ៥
២.១.៣ ទ្រឹស្ដីនៃពន្ធ ........ ៥
២.២ នីតិវិធីក្នុងការប្រមូលពន្ធកាត់ ........ ៦

២.២.១ និយមន័យពន្ធកាត់ទុក........................................................................................ ៦
២.២.២ ប្រវត្តិពន្ធកាត់ទុក................................................................................................ ៦
២.២.៣ ទ្រឹស្តីនៃពន្ធកាត់ទុក ................................................................................................ ៧
២.៣ ផលប្រយោជន៍ក្នុងការប្រមូលពន្ធកាត់ទុក ................................................................................ ៧
២.៣.១ និយមន័យការប្រមូលពន្ធ ........................................................................................ ៧
២.៣.២ ប្រវត្តិនៃការប្រមូលពន្ធ........................................................................................... ៨
២.៣.៣ ទ្រឹស្តីនៃការប្រមូលពន្ធ ............................................................................................ ៨

## ជំពូកទី៣

## នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ ........................................................................ ៩
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ.................................................................................. ៩
៣.១.២ ចក្ខុវិស័យ និងបេសកកម្ម ........................................................................................ ៩
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ ....................១១
៣.២ នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ.............................................. ១៣
៣.២.១ វិធាន និងនីតិវិធី. ........................................................................................................ ១៣
៣.២.២ ផែនការយុទ្ធសាស្ត្រក្នុងការប្រមូលពន្ធ..........................................................................១៦
៣.២.៣ នីតិវិធីក្នុងប្រមូលពន្ធ.................................................................................................. ១៧
៣.២.៤ មូលដ្ឋានគិតពន្ធ អត្រាពន្ធ និងការគណនាពន្ធ............................................................ ២១
៣.២.៥ សិទ្ធអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលពន្ធ ..........................................២៣
៣.៣.៦ ការអនុវត្តពន្ធកាត់ទុកក្នុងករណីដែលមានកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា ................................................................................................................................ ២៤
៣.២.៧ កាតព្វកិច្ចដាក់លិខិតប្រកាស ការបង់ប្រាក់ពន្ធ និងទោសទណ្ឌ .......................... ២៥
៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធកាត់ទុកចំពោះសេដ្ឋកិច្ចជាតិ និងផលប៉ះពាល់ចំពោះអ្នកជាប់ពន្ធ.២៧
៣.៣.១ ផលប្រយោជន៍ក្នុងកាប្រមូលពន្ធកាត់ទុក ...................................................................២៧
៣.៣.២ ការប្រមូលពន្ធកាត់ទុកផ្តល់ផលប៉ះពាល់ដល់អ្នកជាប់ពន្ធ ............................................ ២៩
៣.៣.៣ វិបត្តិសេដ្ឋកិច្ចពិភពលោក.......................................................................................... ៣០

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង...........................................................................................៣២
៤.២ ការវិភាគលើចំណុចខ្សោយ .........................................................................................៣២

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................................ ៣៤
៥.២ ការផ្តល់អនុសាសន៍ ..................................................................................................... ៣៥

**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅពេលដែលសង្គមមនុស្ស ត្រូវបានបែងចែកជាវណ្ណៈ មានការតស៊ូវណ្ណៈ និងមានការកើតឡើងនៃរដ្ឋាភិបាលដើម្បីគ្រប់គ្រងរចនាសម្ព័ន្ធនៃប្រទេសមួយរហូតមកដល់បច្ចុប្បន្ន ពន្ធដារ ត្រូវបានគេអនុវត្តច្រើនបែបយ៉ាងហើយកាន់តែទូលំទូលាយ។ គ្រប់អង្គភាពអាជីវកម្ម ក្រុមហ៊ុន សហគ្រាស ផលិតកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្ម ការប្រកបមុខរបរខ្នាតតូច ធំទាំងអស់ ដែលជាចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវ ចំពោះមុខច្បាប់រដ្ឋក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយ ដែលបានកំណត់ និងមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និងត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយ ដែលមានបែកចែកក្នុងច្បាប់។ នៅក្នុងខឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ។

ជាការពិតណាស់ ពន្ធដារ បានចូលរួមក្នុងការកែសម្រួលខឿនសេដ្ឋកិច្ចជាតិទាំងមូល ដែលបានគ្រប់គ្រងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ យ៉ាងណាមិញ វិស័យពន្ធដារមិនត្រឹមតែជាប្រភពចំណូលដ៏សំខាន់របស់ថវិការដ្ឋតែមួយមុខប៉ុណ្ណោះនោះទេប៉ុន្តែវិស័យពន្ធដារបានផ្សាភ្ជាប់ជាមួយបញ្ហាទាំងឡាយអំពីការបង្កើនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ច អំពីសមាសភាពក្នុងការបែងចែក និងស្ថេរភាពសង្គម។ ប្រសិនបើគោលនយោបាយពន្ធខុសឆ្គង អាចនាំឱ្យមានភាពអន់ថយដល់ខឿនសេដ្ឋកិច្ចសង្គម ផ្ទុយទៅវិញបើគោលនយោបាយពន្ធត្រឹមត្រូវ នាំឱ្យមានភាពសម្បូររុងរឿង និងមានស្ថេរភាពយូរអង្វែងឱ្យប្រទេសជាតិ។ ទន្ទឹមនឹងនេះ ពន្ធដារក្នុងការបង្កើតប្រភពចំណូលថវិកាឱ្យរដ្ឋ ឆ្លងតាមរយៈក្រិតច្បាប់នានា ច្បាប់សារពើពន្ធ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ស្តីអំពីកម្រិតកំណត់អត្រាពន្ធដែលក្រុមហ៊ុន អាជីវកម្ម សេវាកម្ម និងប្រជាពលរដ្ឋដែលជាប់ពន្ធ ត្រូវបង់ពន្ធជូនរដ្ឋហើយប្រាក់នោះត្រូវបានបញ្ជូនចូលក្នុងថវិការដ្ឋតាមរូបភាពជាក់ស្តែងផ្សេងៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ ពន្ធដារនៅប្រទេសកម្ពុជាមានច្រើនប្រភេទដូចជា ពន្ធប៉ាតង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់បៀវត្ស និងមានប្រភេទពន្ធផ្សេងៗទៀត ដូច្នេះហើយដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការកៀគរចំណូលពន្ធជូនរដ្ឋ អគ្គនាយកដ្ឋានពន្ធដារបានកំណត់នូវ ប្រភេទពន្ធ កម្រិតពន្ធ អត្រាពន្ធ ការគណនាពន្ធ ការណែនាំអនុវត្ត ការកែសម្រួលផ្សេងៗ ការដាក់ចេញនូវវិធានការនិងមាននីតិវិធីផ្សេងៗគ្នាក្នុងការប្រមូលពន្ធទៅតាមប្រភេទពន្ធនីមួយៗ។

ដោយមើលឃើញពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើននៃ វិស័យពន្ធដារ ចំពោះសេដ្ឋកិច្ចជាតិបែបនេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តលើកយកប្រភេទពន្ធកាត់ទុកមួយ មកធ្វើការសិក្សាស្រាវជ្រាវឱ្យបានលម្អិតបន្ថែមទៀតអំពីនីតិវិធី ឬវិធីសាស្ត្រក្នុងការដកហូត ឬប្រមូលពន្ធកាត់ទុករបស់អគ្គនាយដ្ឋានពន្ធដារ ក្នុងប្រធានបទមួយក្រោមចំណងជើងថា " ***នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ*** " ដើម្បីទុកជាឯកសារចំណេះដឹងមួយនៃពន្ធកាត់ទុក ជាផ្នែកមួយនៃវិស័យពន្ធដារដែលជាប្រភេទពន្ធមួយមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ ជូនដល់អ្នកសិក្សា សិស្សនិស្សិតជំនាន់ៗក្រោយបានសិក្សាស្វែងយល់ទាំងអស់គ្នា។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ពន្ធ គឺជាប្រភពចំណូលរបស់ថវិការដ្ឋមួយយ៉ាងសំខាន់ ដែលបានរួមចំណែកធ្វើការដោះស្រាយបញ្ហាវិបត្តិសេដ្ឋកិច្ចជាតិផ្សេងៗជាមួយនឹងរដ្ឋាភិបាល។ ការប្រមូលពន្ធ គឺធ្វើឡើងទៅតាមច្បាប់សារពើពន្ធ ដែលមានចែងទៅតាមប្រភេទពន្ធផ្សេងៗគ្នា។ បែបបទបង់ពន្ធ គឺការកំណត់ទទួលខុសត្រូវជាធរមាន និងបែបផែននៃការបង់ពន្ធចូលថវិការដ្ឋ របស់បុគ្គលជាប់ពន្ធ។ គឺជាបែបបទ ធ្វើលិខិតប្រកាសជូនទៅអគ្គនាយកដ្ឋានពន្ធតាមការកំណត់ នៃប្រភេទពន្ធនីមួយៗ និងជាវិធីសាស្ត្រប្រមូលប្រាក់ពន្ធ ដែលផ្សាភ្ជាប់ជាមួយក្របខណ្ឌនៃអំណាច ការទទួលខុសត្រូវនៃស្ថាប័នទាំងឡាយ ដែលមានការពាក់ព័ន្ធ។ អាស្រ័យហេតុនេះហើយទើបមានសំណួរចោទសួរថាៈ

១. តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីក្នុងការប្រមូលពន្ធកាត់ទុកយ៉ាងដូចម្តេច?

២. តើការប្រមូលពន្ធកាត់ទុកបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ និងមានផលប៉ះពាល់អ្វីខ្លះដល់អ្នកជាប់ពន្ធ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដោយយើងសម្លឹងមើលឃើញពីអត្ថប្រយោជន៍ជាច្រើននៃពន្ធ សម្រាប់សង្គមជាតិយើង។ ដូច្នេះហើយ សេចក្តីស្រាវជ្រាវពីប្រភេទពន្ធកាត់ទុកនេះ យើងខ្ញុំមានគោលបំណងចង់ធ្វើការបង្ហាញឱ្យបានយល់ដឹងអំពីៈ

- យល់ដឹងពីសារៈសំខាន់នៃការប្រមូលពន្ធកាត់ទុក
- យល់ដឹងអំពីមូលដ្ឋានគិតពន្ធ អត្រាពន្ធ ការគណនាពន្ធ និងការប្រកាសពន្ធកាត់ទុក
- ដើម្បីស្វែងយល់ពីគោលការណ៍ ច្បាប់ និងបទបញ្ញត្តិរបស់ពន្ធកាត់ទុក
- ស្វែងយល់ពីផលប្រយោជន៍ពីការប្រមូលពន្ធកាត់ទុក
- ស្វែងយល់ផលប៉ះពាល់ពីការប្រមូលពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

បើយើងនិយាយសំដៅទៅពាក្យពន្ធមួយម៉ាត់ គឺមានន័យធំទូលំទូលាយ និងមានច្រើនប្រភេទ ច្រើនសណ្ឋានណាស់។ ដូច្នេះហើយ ក្រុមយើងខ្ញុំបានជ្រើសរើសប្រភេទពន្ធមួយ ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវឱ្យកាន់តែច្បាស់លាស់ ស៊ីជម្រៅបន្ថែមទៀត។ ហើយប្រភេទពន្ធដែលពួកយើងនឹងលើកយកមកធ្វើការវិភាគវែកញែកសាច់រឿងឱ្យកាន់តែលម្អិតនោះ គឺជាប្រភេទពន្ធកាត់ទុក ដើម្បីឱ្យអ្នកអាន អ្នកសិក្សា បានស្គាល់កាន់តែច្បាស់ពីប្រភេទពន្ធនេះ។ ជាពិសេសនោះ ដើម្បីឱ្យប្រជាពលរដ្ឋ ឬម្ចាស់អាជីវករ អាជីវកម្ម ខ្នាតតូច ធំទាំងអស់បានដឹងខ្លួនថាជាប់ពន្ធកាត់ទុកនៅពេលណា ជាប់អត្រាប៉ុន្មានភាគរយ និងចេះពីរបៀបបង់ពន្ធជូនរដ្ឋ។ ដោយក្រុមយើងខ្ញុំបានផ្តោតសំខាន់ទៅលើ នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានទីតាំងនៅទីក្រុងភ្នំពេញ យកមកធ្វើការបកស្រាយ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដោយការសិក្សាស្រាវជ្រាវមួយនេះ តម្រូវឱ្យមានដែនកំណត់ និងវិសាលភាពច្បាស់លាស់ ដូច្នេះហើយ ក្រុមយើងខ្ញុំមិនអាចធ្វើការបកស្រាយបានគ្រប់ប្រភេទពន្ធយ៉ាងទូលំទូលាយនោះទេ។ សម្រាប់ការស្រាវជ្រាវនេះដែរ គឺពួកយើងបានផ្តោតសំខាន់តែទៅលើ នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយដ្ឋានពន្ធដារ តែប៉ុណ្ណោះ ដែលបានដកស្រង់ពេញពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ស្តីពីច្បាប់សារពើពន្ធ ឆ្នាំ២០២៣។

ដើម្បីជាចំណេះដឹងមួយផ្នែកជូនដល់ ប្រជាពលរដ្ឋ ម្ចាស់ក្រុមហ៊ុន អាជីវករ អាជីវកម្ម សហគ្រាស ផលិតកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្ម អ្នកប្រកបមុខរបរខ្នាតតូច ធំទាំងអស់បានយល់ដឹងពីពន្ធកាត់ទុកមួយកម្រិតទៀត។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើវិធីសាស្ត្របែបគុណវិស័យ (Qualitative Methods) ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យដែលបានមកពី សៀវភៅនៅវិទ្យាស្ថានវ៉ាន់ដា ឆ្នាំ២០២៤ ស្តីពីច្បាប់ពន្ធដារនៅកម្ពុជា និងបានមកពីគេហទំព័រចំនួន៤គឺ គេហទំព័រ អគ្គនាយកដ្ឋានពន្ធដារ សៀវភៅណែនាំស្តីពី ច្បាប់សារពើពន្ធ គេហទំព័រ អគ្គលេខាធិការដ្ឋាន គេហទំព័រ RFI និង KhSearch ដែលពាក់ព័ន្ធនឹងប្រធានបទ ដើម្បីយកមកវិភាគក្នុងគោលបំណងបញ្ជាក់ពីនីតិវិធីប្រមូលពន្ធ និងផលប្រយោជន៍ពន្ធកាត់ទុកសម្រាប់សេដ្ឋកិច្ចជាតិ។

### ១.៥.១ បកស្រាយសំណួរទី១

សម្រាប់សំណួរទី១៖ ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន២គឺ គេហទំព័រ អគ្គនាយកដ្ឋានពន្ធដារ ស្តីពីច្បាប់សារពើពន្ធនិងគេហទំព័រ អគ្គលេខាធិការដ្ឋាន និងបានប្រមូលដកស្រង់ចេញពីសៀវភៅពុម្ពនៅវិទ្យាស្ថាន វ៉ាន់ដា ស្តីពីច្បាប់ពន្ធដារនៅកម្ពុជាដើម្បីយកមកដោះស្រាយទៅលើនីតិវិធីក្នុងការប្រមូលពន្ធកាត់ទុក និងការវិភាគទិន្នន័យបន្ទាប់បន្សំ ធ្វើតាមការវិភាគរកប្រធានបទ (Thematic analysis) តាមរយៈការវិភាគរកប្រធានបទដើម្បីសំយោគឯកសារដែលបានមកពី គេហទំព័រទាំងពីរ និងសៀវភៅពុម្ពនៅសាកលវិទ្យាល័យ វ៉ាន់ដារ ក្នុងគោលបំណងបញ្ជាក់ពីការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ។

### ១.៥.២ បកស្រាយសំណួរទី២

- សម្រាប់សំណួរទី២៖ ត្រូវបានប្រមូលតាមគុណវិស័យបានមកពី ប្រភពគេហទំព័រចំនួន២គឺ គេហទំព័រ RFI និង KhSearch ដើម្បីយកមកបកស្រាយទៅលើអត្ថប្រយោជន៍របស់ពន្ធកាត់ ចំពោះសេដ្ឋកិច្ចជាតិ និងការវិភាគទិន្នន័យបន្ទាប់បន្សំ ធ្វើការវិភាគរកប្រធានបទ (Thematic analysis) តាមរយៈការវិភាគរកប្រធានបទដើម្បីសំយោគឯកសារដែលបានមកពីប្រភពគេហទំព័រទាំងពីរក្នុងគោលបំណងបញ្ជាក់ពីផលប្រយោជន៍ក្នុងការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្នុងសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានសារៈសំខាន់ជាច្រើនរួមមាន៖

- ចង់ស្វែងយល់អំពីនីតិវិធីក្នុងការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ
- ចង់យល់ដឹងពីផលប្រយោជន៍នៃការប្រមូលពន្ធកាត់ទុកបានផ្តល់ ក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ
- យល់ដឹងពីប្រភេទអាជីវកម្មដែលត្រូវជាប់ពន្ធកាត់ទុក
- ស្វែងយល់ពីវិធីសាស្ត្រក្នុងការប្រមូលពន្ធឱ្យមានប្រសិទ្ធិភាព
- យល់ដឹងអំពីរបៀបនៃការបង់ពន្ធជូនរដ្ឋ

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានបែងចែកជា៥ជំពូកមានដូចខាងក្រោម៖

**ជំពូកទី១ សេចក្តីផ្តើម៖** ជំពូកនេះបានបង្ហាញអំពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង នៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ព្រមទាំងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ រំលឹកទ្រឹស្តី៖** ជំពូកនេះបានលើកឡើងនូវនិយមន័យនិងទ្រឹស្តីដែលពាក់ព័ន្ធជាមួយនឹងពន្ធដារ និងពន្ធកាត់ទុក។

**ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ៖** ជំពូកនេះបានលើកឡើងអំពី ប្រវត្តិកកើតរបស់អគ្គនាយកដ្ឋាន ពន្ធដារ ពន្ធកាត់ទុក ច្បាប់និងបទបញ្ញត្តិ ការគណនានិងប្រកាសពន្ធកាត់ទុក ក៏ដូចជាការបកស្រាយលម្អិតអំពី នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ និងអត្ថប្រយោជន៍នៃការប្រមូលពន្ធកាត់ទុក ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។

**ជំពូកទី៤ ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ៖** ជំពូកនេះនឹងធ្វើការវិភាគលើ ចំណុចខ្លាំង និងចំណុចខ្សោយនៃនីតិវិធីក្នុងការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍៖** នៅក្នុងជំពូកនេះបានធ្វើការសន្និដ្ឋានដោយសង្ខេបទៅលើគ្រប់ចំណុចដែលបានវិភាគបកស្រាយ និងការផ្តល់ជាមតិយោបល់ទៅលើចំណុចខ្វះខាតដើម្បីកែលម្អ។

# ជំពូកទី២
# ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់ពន្ធដារ

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យរបស់ពន្ធ

ពន្ធ សំដៅដល់ពន្ធ និងអាករទាំងឡាយ។ ពាក្យថា "ពន្ធ" គឺសំដៅដល់ការ កំណត់បន្ទុកហិរញ្ញវត្ថុជាកំហិតដោយរដ្ឋាភិបាលចំពោះ អ្នកជាប់ពន្ធ (រូបវន្តបុគ្គល ឬនីតិបុគ្គល) សម្រាប់ទ្រទ្រង់ការចំណាយរបស់រដ្ឋាភិបាល និងចំណាយលើវិស័យសាធារណៈ ជាច្រើនប្រភេទទៀត[1]។

ពន្ធ (Taxation) គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាលហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ។

ពន្ធ គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

ពន្ធ ជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីកៀរគរចំណូលចូលថវិការជាតិសម្រាប់ចំណាយសាធារណៈ។

ពន្ធ គឺសំដៅទៅលើអាករ (ទាំងពន្ធប្រយោល និងពន្ធផ្ទាល់)។

ពន្ធ គឺជាការបង់វិភាគទាននូវកាតព្វកិច្ច របស់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនិតិបុគ្គលជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់[2]។

### ២.១.២ ប្រវត្តិនៃពន្ធ

ពន្ធ ត្រូវបានរកឃើញដោយប្រទេសអេស៊្សីប។ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងនូវឆ្នាំ១៩៥៣ បន្ទាប់មកប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលក្នុងឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម (ខ្មែរក្រហម និងរបបប៉ុលពត)។ បន្ទាប់មកប្រព័ន្ធពន្ធដារ ត្រូវបានបង្កើតឡើងដំណាក់កាលដំបូងនៅឆ្នាំ ១៩៨០ ដែលបានអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីអនុវត្តនិងមានការបែងចែកច្បាប់ព្រមទាំងមាត្រាយ៉ាងច្បាស់លាស់ផ្អែកលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតនៅរបបកំណត់ដោយពន្ធដារ៣ប្រភេទគឺ៖ របបពិត របបម៉ៅការ និងរបបបំព្រួញដែលបានចែងជាច់ដោយឡែក។ ពន្ធត្រូវបានយកទៅលើ ដីធ្លី ផ្ទះ អចលនទ្រព្យ និងទ្រព្យសម្បត្តិហិរញ្ញវត្ថុជាដើម។ យើងត្រូវមានវិធាន និងនិតិវិធីធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធស្ថិតនៅក្នុងតែរបបមួយ ស្របពេលដែលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងបានប្រកាន់តែរបបពិត (ស្វ័យប្រកាស) តែមួយប៉ុណ្ណោះ[3]។

### ២.១.២ ទ្រឹស្តីនៃពន្ធ

លក្ខណៈសត្យានុម័តៈ ក្រៅពីប្រមូលចំណូលថវិការដ្ឋ ពន្ធគឺជាឧបករណ៍ដែលមានប្រសិទ្ធភាពក្នុងការណែនាំ ផលិតកម្ម អាជីវកម្ម សេវាកម្ម។ បំណែកចែកការប្រើប្រាស់ រួមចំណែកឡើងវិញនូវបញ្ហាការផលិតកម្ម បញ្ហាការសមាមាត្រចំណូលកាន់តែសមស្រប។

---

[1] សន្ធានុក្រមពន្ធដារ (ឆ្នាំ២០២២). *ពន្ធ*. នៅទំព័រទី១៣២

[2] Ngov Socheattey. និយមន័យពន្ធ (១៥ សីហា ២០២២) https://www.youtube.com/watch?v=svJcBEBDmR0

[3] រៀបរៀងដោយនិស្សិតឈ្មោះ ឯក ពិសី, បូ ស្រីដែន, ថន សុគន្ធពេជ្រកន្និកា, ស្រស់ ធីតាវណ្ណ, ចេង លាប. (២០២២). ប្រធានបទ៖ *ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់សាខាពន្ធដារខណ្ឌទួលគោក.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី១៩ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៥. ភ្នំពេញ។

លក្ខណៈអត្ថនោម័តៈ ពន្ធ អនុវត្តការទប់ស្កាត់ សម្របសម្រួលចំណូលរវាងបណ្តាស្រទាប់ប្រជាជន ចូលរួមក្នុងការគ្រប់គ្រងសេដ្ឋកិច្ចទីផ្សារ គ្រប់គ្រងបញ្ជីហិរញ្ញវត្ថុ ថវិការដ្ឋ ធ្វើឱ្យមានភាពស្ថេរភាពថ្លៃ និងចរាចរណ៍ហិរញ្ញវត្ថុ[4]។

តាមទស្សនៈរបស់លោក Charles.M.Allan ពន្ធ គឺជាលំហូរនៃទ្រព្យសម្បត្តិឯកជនទៅកាន់រដ្ឋ លើកលែងតែជាប្រាក់កម្ចីនិងការលក់សេវាកម្មសាធារណៈរបស់រដ្ឋ។

ចំពោះទស្សនៈរបស់លោក E.R.A.Seligman ពន្ធ គឺជាអ្វីៗដែលរដ្ឋធ្វើការកំណត់ប្រមូលមកពីរាស្ត្រ ដើម្បីនាំមកប្រើប្រាស់ជាប្រយោជន៍ដល់សង្គមជាតិ ដោយមិនចំពោះបុគ្គលណាមួយឡើយរួមទាំងអ្នកជាប់ផងដែរ[5]។

## ២.២ នីតិវិធីក្នុងការប្រមូលពន្ធកាត់ទុក

### ២.២.១ និយមន័យពន្ធកាត់ទុក

ពន្ធកាត់ទុក (Withholding Tax) គឺជាពន្ធដែលក្រុមហ៊ុនឬអង្គភាពផ្សេងៗ យកតាមរយៈអតិថិជនឬបុគ្គលពន្ធទាំងមូល និងការប្រើប្រាស់ការកាត់ទុកនោះ ដើម្បីបង់ឱ្យរាជរដ្ឋាភិបាលមុនពេលបង់ប្រាក់ ឬការប្រគល់ប្រាក់ជូនឱ្យអ្នកទទួល។ ជាធម្មតាពន្ធកាត់ទុកគឺនិងប៉ះពាល់ដល់ប្រាក់ចំណូលពីរ ការប្រាក់បង់ប្រាក់ពីប្រាក់ចំណេញ សម្រាប់ករណីពាណិជ្ជកម្ម ឬ ជាប្រាក់ចំណូលឱ្យអ្នកធ្វើការងារ (ការកាត់ទុកពីប្រាក់ឈ្នួល)។

ពន្ធកាត់ទុក គឺពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធនិងនិវាសនជន លើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ឬ ជាវត្ថុឱ្យទៅអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន[6]។

ពន្ធកាត់ទុក (Withholding Tax) គឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធ ដែលមានទីស្នាក់ការក្នុងព្រះរាជាណាចក្រកម្ពុជា ពីការទូទាត់គ្រប់រូបភាព ដែលត្រូវបានដកចេញពីតម្លៃសរុបដែលត្រូវបង់ ហើយត្រូវប្រមូលប្រាក់ពន្ធនោះទៅបង់ឱ្យអគ្គនាយកដ្ឋានពន្ធដារ។

ពន្ធកាត់ទុក គឺជាពន្ធមួយប្រភេទដែល ត្រូវបានអនុវត្តលើចំណូលឬការទូទាត់ថ្លៃសេវាកម្មផ្សេងៗ ទៅបុគ្គលឬសហគ្រាស ឬអង្គការណា ដែលមានសកម្មភាពសេដ្ឋកិច្ច ប្រកបរបររកស៊ីឬផ្តល់សេវាកម្ម ប៉ុន្តែមិនបានចុះបញ្ជីពន្ធដារ ហើយគាត់ទទួលបានការទូទាត់ជា សាច់ប្រាក់ឬជាវត្ថុជាក់លាក់ណាមួយ។

ពន្ធកាត់ទុក ជាពន្ធដែលអាជីវកម្មត្រូវកាត់ចេញពីវិក្កយបត្រទូទាត់មួយចំនួន នៅពេលខ្លួនទទួលសេវាកម្មពីបុគ្គល ឬអាជីវកម្មណាមួយដែលមិនបានចុះឈ្មោះសម្រាប់បង់ពន្ធ។ ពន្ធនេះកាត់បន្ថយចំនួនទឹកប្រាក់លើវិក្កយបត្ររបស់អ្នកទទួល។

### ២.២.២ ប្រវត្តិពន្ធកាត់ទុក

នាយកដ្ឋានពន្ធដារ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៣ ប៉ុន្តែមិនបានប៉ុន្មាន ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម (ខ្មែរក្រហមនិងរបបប៉ុលពត) ។ ដោយយោងទៅលើច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តប្រកាសឱ្យប្រើប្រាស់ជាលើកដំបូង នៅក្នុងខែវិច្ឆកា ឆ្នាំ១៩៨២ និងបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ១៩៨៣។ ច្បាប់ទាំង៣នោះមានដូចជា ពន្ធលើធុរៈកិច្ច ពន្ធលើអាហារណ៍ និងពន្ធលើផលិតផលកសិកម្ម។ នៅក្នុងច្បាប់បានចែងថា គ្រប់សហគ្រាសឯកជន ដែលបាន

[4] វ៉ែន ឈុនហួត. Weebly. *សញ្ញាណទូទៅនៃពន្ធដារ.* Retrieved July, 31 2025 from https://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf

[5] Linked ln. Sarith Khem. (2018, January 31). *និយមន័យពន្ធដារ.* Retrieved July, 31 2025 from https://url-shortener.me/4SPA

[6] គ.ជ.អ.ប. អគ្គនាយកដ្ឋានពន្ធដារ (២០១៣). *តើពន្ធកាត់ទុកគឺជាអ្វី?* Retrieved July, 31 2025 from https://www.tax.gov.kh/km/faq#

ធ្វើសកម្មភាពសេដ្ឋកិច្ចទាំងអស់ត្រូវមាន កាតព្វកិច្ចបង់ប្រាក់ពន្ធ ក្នុងខណៈពេលដែលកំណត់លើសារពើពន្ធនៃប្រភពចំណូល ដែលបានមកពីការនាំចូលទំនិញនិងផលិតផលកសិកម្ម ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអ្នកទទួលខុសត្រូវលើការកំណត់ពន្ធនិងការប្រមូលពន្ធ។ ហើយពន្ធកាត់ទុកមានប្រវត្តិចាប់ផ្តើមដំបូងគឺ ចេញពីព្រះរាជក្រមលេខ នស.រកម.០២៩៧/ថ្ងៃទី២៤/២/១៩៩៧ ដោយសារតែផ្តត់ផ្តង់ក្រោមរូបភាពរូបវន្តបុគ្គល (ឯកបុគ្គល ក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល) បានទទួលប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលក្រៅកម្ពុជា មិនបានទៅប្រកាសបង់ពន្ធឱ្យបានត្រឹមត្រូវជូនរដ្ឋបាលសារពើពន្ធទេ ពិសេសទាក់ទងនឹងប្រាក់ចំណូលដូចមានចែងក្នុងមាត្រាទី២៥ ហេតុនេះទើបរដ្ឋបង្កើតច្បាប់ពន្ធកាត់ទុកឡើង[7]។

#### ២.២.៣ ទ្រឹស្តីនៃពន្ធកាត់ទុក

សរុបមក ពន្ធកាត់ទុក ជាប្រភេទពន្ធផ្ទាល់ ដែលរដ្ឋតម្រូវឱ្យបុគ្គលដែលជាប់ពន្ធត្រូវបង់ជាប្រចាំខែ ចំពោះការគិតពន្ធនេះត្រូវគណនាដោយផ្អែកទៅតាមប្រាក់ជាប់ពន្ធជាក់ស្តែង និង យោងទៅតាមអត្រាជាប់ពន្ធ ដែលមានកំណត់ជាក់ស្តែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធ ហើយប្រាក់ដែលបានប្រមូលមក គឺរដ្ឋបានចាត់ចែងដូចជាបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ សាងសង់សាលារៀន មន្ទីពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត[8]។

### ២.៣ អត្ថប្រយោជន៍ក្នុងការប្រមូលពន្ធកាត់ទុក

#### ២.៣.១ និយមន័យការប្រមូលពន្ធ

ការប្រមូលពន្ធ គឺជាការកៀគរចំណូលពន្ធ ឬការដកហូតប្រាក់ពន្ធពីប្រជាពលរដ្ឋ ឬបណ្តាអ្នកជាប់ពន្ធទាំងអស់ ដើម្បីយកទៅបង់ជូនអគ្គនាយកដ្ឋានពន្ធដារ ឬតាមសាខាពន្ធ ឬជាការប្រមូលប្រាក់ពន្ធទាំងនោះបញ្ជូនចូលទៅក្នុងថវិការបស់រដ្ឋ ដើម្បីឱ្យរដ្ឋាភិបាលមានលទ្ធភាពក្នុងការចាត់ចែងលើចំណាយផ្សេងៗដែលសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូល។

ពន្ធកាត់ទុកត្រូវបានប្រមូល ដើម្បីយកទៅបង់ឱ្យអគ្គនាយកដ្ឋានពន្ធដារ។ ហើយអ្នកជាប់ពន្ធនិវាសនជនក៏អាចដកហូតពន្ធកាត់ទុកពីអ្នកផ្គត់ផ្គង់និវាសនជននិងអនិវាសនជនបានដែល។

ការប្រមូលពន្ធកាត់ទុក គឺត្រូវបានប្រមូលពីអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជនទៅលើការទូទាត់ប្រាក់ចំណាយមួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឱ្យអ្នកជាប់ពន្ធនិវាសនជន (ជនជាតិខ្មែរ) និងអនិវាសនជន (ជនជាតិបរទេសដែលបានមករស់នៅក្នុងប្រទេសកម្ពុជា) ដែលបានប្រកបអាជីវកម្មទាំងអស់។

ការប្រមូលពន្ធ គឺជាប្រមូលប្រាក់ពីប្រជាជន ឬអាជីវកម្មដោយរដ្ឋ ដើម្បីធ្វើការគ្រប់គ្រង និងផ្តល់សេវាសាធារណៈដល់ប្រជាជន។ ពន្ធដែលប្រមូលបានត្រូវសម្រាប់ការវិនិយោគក្នុងវិស័យផ្សេងៗដូចជា សុខាភិបាល ការបណ្តុះបណ្តាល ដំណើរផ្លូវចរាចរណ៍ និងសេវាសាធារណៈផ្សេងៗ។

---

[7] រៀបរៀងដោយនិស្សិតឈ្មោះ ខាចាន់ វិច្ឆិកា, ធា ស៊ាវឈិញ, សួន ម៉ៅស្រីម៉ាច, ឈាង ឆៃយ៉ា. (២០២៣). ប្រធានបទ៖ *ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់ពន្ធដារសាខាខណ្ឌទួលគោក*. សាណារបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២០ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៩. ភ្នំពេញ។

[8] FRESH NEWS. រៀបរៀងដោយ៖ លោកស្រីមេធាវី យ៉េ នីតា និង លោក ថន ផានិត ជាជំនួយការមេធាវី និងជាសមាជិកក្រុមការងារ (១៤ មករា ២០២៤). *ផ្អែកយល់ដឹងពីពន្ធកាត់ទុក*. Retrieved from https://m.freshnewsasia.com/freshnewsplus/325035-2024-01-14-10-07-25.html

ការប្រមូលពន្ធ គឺជាការប្រមូលប្រាក់ចំណូលសម្រាប់រដ្ឋាភិបាល ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងសង្គម ពន្ធត្រូវបានប្រមូលពីបុគ្គល និងសាជីវកម្មតាមរយៈពន្ធផ្ទាល់ និងពន្ធប្រយោល[9]។

**២.៣.២ ប្រវត្តិនៃការប្រមូលពន្ធ**

ពន្ធដារ មានប្រវត្តិសាស្ត្រទៅនឹងដំណើរការវិវត្តន៍របស់សង្គម ចិត្តសាស្ត្រមនុស្ស សេដ្ឋកិច្ច និងតួនាទីរបស់រាជរដ្ឋាភិបាល។ ពន្ធដារនៅកម្ពុជា កកើតឡើងតាំងពីមហានគរមកម្ល៉េះ ប៉ុន្តែក្នុងសម័យនោះ ពន្ធមិនត្រូវបានគេហៅថាពន្ធដារនោះទេ។ កាលរាជានិយមខ្មែរសម័យអង្គរដែលកំណត់លើទៅលើ ប្រទេសឡាវ សៀម(ថៃ) ភូមា និងសូម៉ាត្រាខាងកើត នូវជង្វាយមួយឆ្នាំសម្រាប់ការជ្រោកកោនក្រោមម្លប់ដ៏ត្រជាក់ និងសុខសាន្តរបស់ពួកគេពីការឈ្លានពាននៃប្រទេសដទៃទៀតដោយមានការការពារពី មហានគរយ៉ាងរឹងមាំ ជង្វាយទាំងនោះហើយដែលបច្ចុប្បន្នយើងហៅថាពន្ធ។ ក្រោយមកក្នុងកំឡុងឆ្នាំ ១៩២៥ ប្រទេសកម្ពុជាយើងក៏ដូចជាប្រទេសដទៃទៀតក្នុងឥណ្ឌូចិនស្ថិតក្រោមអាណានិគមន៍បារាំង ហើយវិបត្តិនៃការប្រមូលពន្ធបានកើតឡើងនៅប្រទេសកម្ពុជាយើង។ ក្រោយទទួលឯករាជ្យពីបារាំងឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាបានរៀបចំបង្កើតនាយកដ្ឋានពន្ធគយរដ្ឋាករ និងពន្ធដារ ដំបូងបំផុតនៅក្នុងប្រទេសដោយសារតម្រូវការកំណើនសេដ្ឋកិច្ច។ ចន្លោះឆ្នាំ ១៩៧៥-១៧៩ ប្រព័ន្ធពន្ធដារ ការប្រមូលពន្ធត្រូវបានលុបបំបាត់(ភាពទុំមុនស្រគាលនៃអ្នកនយោបាយខ្មែរបានធ្វើឱ្យប្រជារាស្ត្រ និងប្រទេសធ្លាក់ក្នុងសង្គ្រាម)។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ អ្វីៗគ្រប់យ៉ាងនៅកម្ពុជា គឺចាប់ផ្តើមពីបាតដៃទទេ ហើយក៏មានវិវត្តន៍ ការផ្លាស់ប្តូរឈ្មោះនាយកដ្ឋានជាច្រើនដំណាក់កាល រហូតដល់ឆ្នាំ ១៩៩៤ របបប្រមូលពន្ធត្រូវបានដាក់ឱ្យអនុវត្តតរៀងមក[10]។

**២.៣.៣ ទ្រឹស្តីនៃការប្រមូលពន្ធ**

ការប្រមូលពន្ធ មានលក្ខណៈបង្ខំដោយស្របច្បាប់ និងជាការប្រមូលដោយផ្ទាល់ ឬដោយប្រយោល ដែលប្រជាពលរដ្ឋគ្រប់រូប ឬអ្នកជាប់ពន្ធគ្រប់ប្រភេទត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវលើបង់ពន្ធជូនរដ្ឋ ទៅតាមប្រភេទពន្ធដែលខ្លួនជាប់ ដោយមិនអាចប្រកែកតវ៉ាបានឡើយ។

[9] រៀបរៀងដោយនិស្សិតឈ្មោះ ខាចាន់ វិច្ឆិកា, ធា ស៊ាវឈិញ, សួន ម៉ៅស្រីម៉ាច, ឈាង ឆៃយ៉ា. (២០២៣). ប្រធានបទ៖ *ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់ពន្ធដារសាខាខណ្ឌទួលគោក*. សាណារបញ្ចាប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២០ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៩. ភ្នំពេញ។

[10] រៀបរៀងដោយសាស្ត្រាចារ្យ សៅ សុភាព. សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (៩ មិថុនា ២០២១) *សញ្ញាណទូទៅនៃពន្ធ*. ភ្នំពេញ។

# ជំពូកទី៣

# ដំណើរការនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ




រូបភាពទី១៖ អគ្គនាយកដ្ឋានពន្ធដារ

- ១៩៥៣ : នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង
- ១៩៧៥-១៩៧៩ : ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់
- ១៩៩៣-២០០៨ : នាយកដ្ឋានពន្ធដារ (អង្គភាពពន្ធដារ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ២០០៨ : ដំឡើងទៅជាអគ្គនាយដ្ឋានពន្ធដារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៣.១.២ ចក្ខុវិស័យ និងបេសកកម្ម

ក. ចក្ខុវិស័យ

អគ្គនាយកដ្ឋានពន្ធដារនិងរដ្ឋករកម្ពុជា មានចក្ខុវិស័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខ្លួនឱ្យក្លាយជារដ្ឋបាលគយទំនើបឈានមុខក្នុងការផ្តល់សេវា ដើម្បីពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម ចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងរួមចំណែក ការពារសង្គមប្រកបដោយចីរភាព និងប្រសិទ្ធភាព។

ខ. បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- សម្រួលពាណិជ្ជកម្មនិងរួមចំណែកបង្កឱ្យមានបរិយាកាសធុរៈកិច្ចល្អប្រសើរ
- បង្កើនប្រសិទ្ធភាពក្នុងការប្រមូលចំណូលពន្ធអាករប្រកបដោយសមធម៌ តម្លាភាព
- បង្កើនប្រសិទ្ធភាពក្នុងការបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ
- ចូលរួមចំណែកការពារសង្គម បរិស្ថាន និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា
- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទបញ្ញត្តិ នានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការទាមទារ និងអនុវត្តទោសទណ្ឌតាមការកំណត់ នៃបទបញ្ញត្តិស្តីពីពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិតាមត្រឹមត្រូវតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តគោលការណ៍យុត្តិធម៌ ក្នុងការអនុវត្តច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទបញ្ញត្តិស្តីពីសារពើពន្ធ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តន៍ត្រឹមត្រូវនូវច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ និងការបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ ប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។



### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទីនិងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ

ក. រចនាសម្ព័ន្ធគ្រប់គ្រង

អគ្គនាយដ្ឋានពន្ធដារ មានរចនាសម្ព័ន្ធគ្រប់គ្រងតាមចំណាត់ថ្នាក់ដូចខាងក្រោម៖

- **ឯកឧត្តម គង់ វិបុល:** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- **ឯកឧត្តម អ៊ុំ សីហា:** អគ្គនាយករង
- **ឯកឧត្តម ជា ដារ៉ុជ:** អគ្គនាយករង
- **ឯកឧត្តម មិញ បានកុសល:** អគ្គនាយករង
- **ឯកឧត្តម កែន សម្បត្តិ:** អគ្គនាយករង
- **ឯកឧត្តម ហេង សុខណាង:** អគ្គនាយករង
- **ឯកឧត្តម រ័ត្នមុនី:** អគ្គនាយករង
- **ឯកឧត្តម លឹម ហ៊ុយជីវ:** អគ្គនាយករង
- **លោក លឹម ជីលុច:** អគ្គនាយករង
- **លោក ហឹម ប៊ុនធឿន:** នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- **លោក សេង ជាសិទ្ធ:** នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដាអន្តរជាតិ
- **លោក ខឹម តុលា:** នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- **លោក បាន ឌី រិទ្ធ:** នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- **លោក ស្រុន អង្គរ៉េន:** នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដា
- **លោក ជ័យ រិទ្ធី:** នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- **លោក តែ ហ្សឺឌី:** នាយកដ្ឋានសវនកម្មសហគ្រាស
- **លោក សុន វុទ្ធី:** សាលាជាតិពន្ធដារ
- **លោក ហាន ត្រេង:** ប្រធានទីចាត់ការពន្ធដាររាជធានីភ្នំពេញ
- **លោក រៀម រដ្ឋា:** នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- **លោក អេង រតនា:** នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

## ខ. កម្រងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋាន




រូបភាពទី២៖ រចនាសម្ព័ន្ធអគ្គនាយដ្ឋានពន្ធដារ

## ខ. តួនាទី និងភារកិច្ច របស់អគ្គនាយលដ្ឋានពន្ធដារ

❖ តួនាទីរបស់ពន្ធដារមានពាគឺ

- ជួយជម្រុញកំណើនសេដ្ឋកិច្ច
- ទប់ស្កាត់ការនាំចូល ការនាំចេញ និងរក្សាតុល្យភាព ចំណូលរបស់ប្រជាពលរដ្ឋ
- ជាប្រភពចំណូលដ៏សំខាន់សម្រាប់ថវិកាជាតិ។

❖ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចតទៅ:

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្ដីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និង លិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្ដល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្ដុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ

- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ នីតិវិធីនៃការប្រមូលពន្ធកាត់ទុករបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ វិធាន និងនីតិវិធី

➢ **កម្មវត្ថុនៃពន្ធ**

- ពន្ធកាត់ទុក (Withholding tax) គឺជាប្រភេទពន្ធលើប្រាក់ចំណូលដែលត្រូវបានប្រមូលតាមរយៈការកាត់ទុកពីអ្នកទទួលប្រាក់ចំណូល។ ពន្ធកាត់ទុកជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិវាសនជនដែលជាភ្នាក់ងារកាត់ទុក ចំពោះការទូទាត់ឲ្យដល់អ្នកជាប់ពន្ធនិវាសនជន និងឱ្យទៅអ្នកជាប់ពន្ធអនិវាសជន។

- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់។

- ប្រតិបត្តិការណាដែលជាកម្មវត្ថុនៃពន្ធកាត់ទុកដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។

➢ **ប្រាក់ចំណូលប្រភពកម្ពុជា**

១. ការប្រាក់ដែលបង់ដោយអ្នកជាប់ពន្ធនិវាសជន ក្រុមហ៊ុនសហកម្មសិទ្ធនិវាសជន ឬស្ថាប័នរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

២. ភាគលាភដែលបានបែងចែកដោយអ្នកជាប់ពន្ធ និវាសនជន។

៣. ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេសដែលបានទូទាត់ដោយអ្នកជាប់ពន្ធ និវាសនជន។

៥. ប្រាក់ចំណូលដែលបានមកពី ចលនទ្រព្យ ឬអចលនទ្រព្យ ក្នុងករណីទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦.ប្រាក់សួយសារបានមកពីការប្រើប្រាក់ ឬសិទ្ធប្រើប្រាស់ទ្រព្យសកម្មអរូបី ដែលបានទូទាត់ដោយបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

៧. ផលចំណេញពីការលក់ចលនទ្រព្យ និងអចលនទ្រព្យ រួមទាំងទ្រព្យអរូបីដែល ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យ និងអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៩. ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែក នៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធ អនិវាសជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០. ការប្រាក់ចំណូលពីសកម្មភាពអាជីវកម្ម របស់អ្នកជាប់ពន្ធអនិវាសជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

➢ **ប្រាក់ចំណូប្រភពបរទេស**

ប្រាក់ចំណូលប្រភពបរទេស ដែលមិនត្រូវបានកំណត់ថាជាប្រាក់ចំណូលប្រភពកម្ពុជា ដូចមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះ ត្រូវបានចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

➢ **ការលើកលែងពន្ធកាត់ទុក**

- ការប្រាក់ដែលបានបង់ឱ្យធនាគារក្នុងស្រុក និងការទូទាត់ប្រាក់ចំណូលលើកលែងពន្ធ
- ការបើក ឬទូទាត់ឱ្យរាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាលនូវស្នួយសារ ឬប្រាក់ឈ្នួលលើចលនទ្រព្យដែលបានបំពេញលក្ខខ័ណ្ឌទាំងពីរដូចតទៅ៖

១. ការបើកឬទូទាត់ប្រាក់នេះត្រូវទាក់ទិននិងចលនទ្រព្យឬអចលនទ្រព្យបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋ

២. ការបើកឬទូទាត់ត្រូវបានបញ្ជាក់បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- ការបើក ឬទូទាត់ពីប្រាក់ចំណូលពីប្រាក់បៀវត្ស ឬអត្ថប្រយោជន៍បន្ថែម
- ប្រាក់ចំណូលពីអង្គការណាមួយដែល

ក/ ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទសាធខាងសាសនា សប្បុរធម៌ វិទ្យាសាស្រ្ត អក្សរសាស្រ្ត ឬអប់រំ

ខ/ គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន

- ប្រាក់ចំណូលរបស់សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គភាពទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៏ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល
- ភាគលាភដែលទទួលមកពីសហគ្រាសនិវាសជនក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា ២២,២៣ និងមាត្រា២៦ នៃច្បាប់ត្រូវបានបង់រួចរាល់
- ការទូទាត់ប្រាក់ចំពោះការផ្គត់ផ្គង់សេវាណាមួយតម្លៃក្រោម ៥០,០០០រៀល
- ការលើកលែងពន្ធកាត់ទុកចំពោះប្រាក់ចំណូលរបស់សហគ្រាសអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា

ក. ចំពោះប្រាក់ចំណូលបានមកពីការបំពេញសេវានានា

ខ. ប្រាក់ចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យ

គ. ប្រាក់ចំណូលពីការផ្គត់ផ្គង់សូហ្វវែរមានលក្ខណៈដូចជា(Shrink-wrap Software, Site License, Downloadable, Software, Software Bundled with Computer Hardware)

- ថ្លៃឈ្នួលចលនទ្រព្យ បង់ឱ្យក្រុមហ៊ុនភិតិសន្យាហិរញ្ញវត្ថុ
- បិព្វលាភធានារ៉ាប់រ៉ងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅក្នុងព្រះរាជាណាច្រកម្ពុជា
- ចំពោះអ្នកជាប់ពន្ធតូច៖ មិនមែនកាតព្វកិច្ចកាត់ទុកចំពោះចំណាយជាប់ពន្ធកាត់ទុក លើកលែងតែការជួលចលនទ្រព្យ ឬអចលនទ្រាព្យតាមអត្រា១០ភាគរយ។

➢ **ការចុះបញ្ជីពន្ធ**

១. បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីការទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថានប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអាទិ៍ដូចជា៖

ក. ស្ថាប័នរដ្ឋបេសកម្មទូតកុងសុលបរទេស អង្គការអន្តរជាតិទីភ្នាក់ងារប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុនបរទេស ការិយាល័យតំណាង សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហគ្រាសសាធារណ: សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

គ. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ. បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២. បុគ្គលដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រកាសនេះត្រូវបានតម្រូវអោយចុះបញ្ជីពន្ធដារស្របតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបប ដូចមានចែងក្នុងច្បាប់និងបញ្ញត្តិស្តីពីពន្ធដារ និងស្នើរសុំចុះបញ្ជីទៅតាមទ្រង់ទ្រាយគតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោមៈ

ក. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ នៃប្រកាសនេះ ការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្ម https;//www.registrationservices .gov.kh ស្របទៅតាមការកំណត់ដូចមានចែងក្នុងអនុក្រិតលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ បុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្ម និងទទួលបានឯកសារបញ្ជាក់ ការចុះបញ្ជីពន្ធដារជាទម្រង់ឌីជីថល ដែលអាចបោះពុម្ពបានតាមគេហទំព័រចុះអាជីវកម្មនេះ។

ខ. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌ គ និងវាក្យខណ្ឌ នៃកថាខណ្ឌ១ នៃប្រកាសនេះ ឬបុគ្គលណាមួយដែលមានបំណងចង់ធ្វើការចុះបញ្ជីដោយផ្ទាល់ នៅរដ្ឋបាលសារពើពន្ធ ឬមិនអាចធ្វើចុះបញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន ការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈ ការបំពេញព័ត៌មាននិងភ្ជាប់ឯកសារតម្រូវដូចមានកំណត់ក្នុងពាក្យស្នើរសុំចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (ទម្រង់ ១០១) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធ កម្រៃសេវាដោយបញ្ជាក់កាលបរិច្ឆេទ នៃការប្រគល់ទទួលបន្ទាប់ពីបានពិនិត្យឃើញថាសំណុំឯកសារស្នើរសុំនោះត្រឹមត្រូវ និងគ្រប់គ្រាន់។ ដោយឡែក ការស្នើរសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រកាសនេះ រដ្ឋបាលសារពើពន្ធ ត្រូវបំបែងឯកសារ បញ្ចូលព័ត៌មានការស្នើរសុំចុះបញ្ជី និងសម្របសម្រួលទូទាត់ប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជីនៅតាមគេហទំព័រចុះបញ្ជីអាជីវកម្ម https;//www.registrationservices .gov.kh ឱ្យបានរួចរាល់និងត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើរសុំចុះបញ្ជី និងប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជី នៅក្រោយពេលបានទទួលលិខិតជាសារអេឡិចត្រូនិកបញ្ជាក់ការទទួលពាក្យស្នើរសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។




### ៣.៣.២ ផែនការយុទ្ធសាស្រ្តក្នុងការប្រមូលពន្ធ

ដើម្បីបន្តធានាបាននូវនិរន្តរភាពនៃការប្រមូលចំណូលពន្ធក្នុងស្រុក ឱ្យស្របតាមការកើនឡើងឥតឈប់ឈរនៃតម្រូវការថវិការជាតិ ក៏ដូចជាការឆ្លើយតបទៅនិងបរិការណ៍សង្គមសេដ្ឋកិច្ចឌីជីថល អគ្គនាយកដ្ឋានពន្ធដារបានយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការរិះរកផ្តួចផ្តើមដាក់ចេញនូវវិធានការដែរមានប្រសិទ្ធិខ្ពស់ក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់ ជូនអ្នកជាប់ពន្ធ ដើម្បីកាត់បន្ថយបន្ទុកចំណាយលើការបំពេញកាតព្វកិច្ច និងនីតិវិធីសារពើពន្ធ និងបន្តពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុទ្ធស្តីពីពន្ធដារជាធរមាន តាមការអនុវត្តស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីបង្កើនការប្រកួតប្រជែងស្មើភាព និងលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។

តម្លាភាព និងភាពងាយស្រួលក្នុងការស្វែងយល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ លើកកម្ពស់ក្នុងការបំពេញ អនុលោមភាពសារពើពន្ធ។ ជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវការរៀបចំចងក្រងច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០២៣ ដែលធានាបាននូវភាពប្រទាក់ក្រឡាគ្នាជាមួយនឹងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាន និងជាការធ្វើបច្ចុប្បន្នភាពច្បាប់នេះឱ្យឆ្លើយតបនឹងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច។ ទោះបីជាអគ្គនាយកដ្ឋានពន្ធដារបានខិតខំផ្តល់សេវាជូនអ្នកជាប់ពន្ធ និងអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងពន្ធដារដូចមានរៀបរាប់ខាងលើក៏ដោយក៏ការលើកកម្ពស់គុណភាពសេវាក៏ដូចជាការគិតគូរលើការរៀបចំគោលនយោបាយសារពើពន្ធបន្ថែមទៀត នៅតែត្រូវបានចាត់ទុកថាជាគោលបំណងអាទិភាពបំផុតដើម្បីចូលរួមកាត់បន្ថយបន្ទុក និងកសាងទំនុកចិត្តជូនអ្នកជាប់ពន្ធនៅក្នុងបរិការណ៍នៃការវិវត្តសេដ្ឋកិច្ច និងសង្គមឌីជីថល។ ដើម្បីសម្រេចគោលដៅនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវយុទ្ធសាស្រ្តដូចខាងក្រោម៖

យុទ្ធសាស្រ្តទី១៖ លើកកម្ពស់ការផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន ឱ្យស្របតាមការវិវត្តនៃបរិបទធុរកិច្ច

យុទ្ធសាស្រ្តទី២៖ លើកកម្ពស់វប្បធម៌នៃការបង់ពន្ធតាមរយៈការផ្តល់សេវាបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលនយោបាយ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

យុទ្ធសាស្រ្តទី៣៖ លើកកម្ពស់ការឆ្លើយតបរាល់ចម្ងល់ និងបញ្ហាផ្សេងៗរបស់អ្នកជាប់ពន្ធ ឱ្យមានការឯកភាពគ្នា។

យុទ្ធសាស្ត្រទី៤៖ លើកកម្ពស់ការផ្តល់សេវាប្រកបដោយគុណភាពតាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រសេវាអ្នកជាប់ពន្ធ។

យុទ្ធសាស្ត្រទី៥៖ លើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ ភាគីពាក់ព័ន្ធនានា។

យុទ្ធសាស្ត្រទី៦៖ កំណត់តម្រូវការ និងភាពពេញចិត្តរបស់អ្នកជាប់ពន្ធ ចំពោះការផ្តល់សេវារបស់អគ្គនាយកដ្ឋានពន្ធដារ។

យុទ្ធសាស្ត្រទី៧៖ លើកកម្ពស់បរិយាកាសពន្ធដារតាមរយៈការចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារ។

**៣.២.៣ នីតិវិធីក្នុងការប្រមូលពន្ធ**

ដើម្បីប្រមូលពន្ធមានប្រសិទ្ធភាព និងការប្រមូលពន្ធដំណើរការដោយរលូន ពន្ធដារត្រូវរៀបចំផែនការដូចខាងក្រោម៖

**ក.ការប្រមូលពន្ធ**

- ពន្ធដារគ្រប់គ្រងការប្រមូលពន្ធតាមមុខងារប្រតិបត្តិស្នូល និងគាំទ្រតាមចំណាត់ថ្នាក់ តាមអ្នកជាប់ពន្ធ
- មុខងារប្រតិបត្តិស្នូល៖ ធ្វើសវនកម្មប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ាច្បាប់ និងគោលនយោបាយ
- មុខងារគាំទ្រ៖ ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ ធនធាន
- ប្រាក់ពន្ធប្រមូលដោយរដ្ឋបាលសារពើពន្ធ ថ្នាក់អគ្គនាយកដ្ឋានសាខាពន្ធខេត្ត-ខណ្ឌ
- ការបង់ពន្ធត្រូវបានកំណត់ដូចតទៅ៖

១. ប្រាក់ពន្ធត្រូវកំណត់និងបង់ នៅក្នុងរយៈពេលដែលបទបញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ

២. បំណុលសារពើពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទាមទារបំណុល

៣. ប្រាក់ពន្ធដែលត្រូវកំណត់ដែលត្រូវបង់ក្នុងរយៈពេល៣ថ្ងៃក្រោយ ពីការប្រគល់លិខិតជូនដំណឹងទាមទារបំណុល

៤. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធ្វើការកំណត់ដោយប្រកាសនូវវិធាន និងនីតិវិធីដើម្បី៖

ក. កំណត់ការបរិច្ឆេទទាមទារបំណុលពន្ធ ដើម្បីចៀសវាងការខាតបង់ ដោយទាមទារបំណុលពន្ធមិនបាន

ខ. ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន។

-ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធករ របស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ដោយរំលោភទៅលើបទបញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធករទាំងនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់។

**ខ.ការកំណត់ពន្ធ**

- ចំនួនប្រាក់ពន្ធត្រូវកំណត់ដូចតទៅ៖

១. ក្នុងករណីដែល ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធមានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺការកំណត់ចំនួនទឹកប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន

២. ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកគឺជាភារៈកំណត់ពន្ធដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបានគណនាទៅលើលិខិតប្រកាសសារពើពន្ធដែលដាក់ជូនទៅរដ្ឋបាលសារពើពន្ធ

៣. ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែធ្វើលិខិតប្រកាសមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬឯកសារផ្សេងទៀតតាមតម្រូវការ ឬមិនផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងប្រគល់ឱ្យបុគ្គលនោះការកំណត់ពន្ធឯកតោភាគីផ្អែកលើះ

ក. ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងទៀតដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ។

ខ. ព័ត៌មានដែលមាននៅក្នុងលិខិតប្រកាសព័ត៌មាន។

គ. ព័ត៌ផ្សេងទៀតដែលរដ្ឋបាកសារពើពន្ធបានទទួល។

៤. បើសិនជាមានមូលដ្ឋានបញ្ជាក់ថាការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធនៅពេលណាមួយក៏បាន។

- ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញត្រូវកំណត់ដូចតទៅះ

១.ចំពោះការកំណត់ពន្ធផ្អែកលើតាមនៃមាត្រា១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធ អាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣ឆ្នាំបន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង ។

២. ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខណ្ឌ២ និងកថាខណ្ឌ៣នៃមាត្រា១១៦ នៃច្បាប់នេះរដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេលណាមួយខាងក្រោមនេះ

ក. ក្នុងរយៈពេល៣ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ

ខ. ក្នុងរយៈពេល១០ឆ្នាំក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

គ. ក្នុងរយៈពេលណាមួយក៏បានតាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកជាប់ពន្ធ ។

៣. អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកអាចស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសសារពើពន្ធក្នុងរយៈពេល៣ឆ្នាំក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខណ្ឌ២នៃមាត្រា១១៦នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុនសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្តាលឱ្យមានការបង្វិលសងប្រាក់ពន្ធ ឬឥណទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមនីតិវិធីត្រួតពិនិត្យសារពើពន្ធ ។

៤. អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣ឆ្នាំក្រោយកាលបរិច្ឆេទផលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញដោយផ្អែកលើព័ត៌មានបន្ថែមដល់អ្នកជាប់ពន្ធឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ ។

៥. ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតម្រូវការកំណត់ពន្ធឡើងវិញ អាជ្ញាយុកាលនៃការកំណត់ពន្ធឡើងវិញក្នុងកថាខណ្ឌ១ និងកថាខណ្ឌ២នៃមាត្រានេះត្រូវចាប់ផ្តើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ។

- ការកំណត់ពន្ធឡើងវិញ ត្រូវមានដំណើរការតាមនីតិវិធីដូចតទៅ៖

១. រដ្ឋបាលសារពើពន្ធ ត្រូវជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ

២. អ្នកជាប់ពន្ធមានរយៈពេល៣០ថ្ងៃដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅតាមការិយាល័យរបស់នាយកដ្ឋានពន្ធដារ ដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនេះក្នុងរយៈពេលនេះអ្នកជាប់ពន្ធអាចទទួលយកឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធ ត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធ ឡើងវិញបើសិនជាពុំបានឆ្លើយតប។

៣. បើសិនជាមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារតាមនីតិវិធីដែលមានចែងក្នុងមាត្រា១២០ នៃច្បាប់នេះ ។

៤. ការិយាល័យទទួលបន្ទុកការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានពន្ធដារត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញទៅការិយាល័យប្រមូលពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ។

- នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធ ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ ដែលរដ្ឋបាលសារពើពន្ធមានបន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ។ នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធ ឬប្រាក់ចំណូលដែលបានប្រកាស ដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្ម ឬវត្ថុនានាដែលធ្វើឱ្យឃើញពីចំណាយរបស់អ្នកជាប់ពន្ធឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅ និងទំហំនៃចំណាយដើម្បីទ្រព្យសកម្មឬវត្ថុនានាដែលលិចធ្លោនោះ។

### គ. ការធ្វើសវនកម្មពន្ធ

- បន្ទាប់ពីដាក់លិខិតប្រកាសពន្ធ ក្នុងករណីអ្នកជាប់ពន្ធមានការប្រកាសពន្ធស្មោះត្រង់អ្នក ជាប់ពន្ធអាចទទួលរងការធ្វើសវនកម្មពន្ធដារ។ សវនកម្មពន្ធដារមាន ៣ប្រភេទ៖

- ការត្រួតពិនិត្យលើលិខិតស្នាម(Desk Audit)
- ការធ្វើសវនកម្មមានកម្រិត(Limited Audit)
- ការធ្វើសវនកម្មពេញលេញ(Comprehensive Audit)

### ឃ. ការបង្ការហានិភ័យពេលប្រមូលពន្ធ

នៅតាមបណ្តាលប្រទេសនីមួយៗនៅលើសកលលោក គ្រប់ប្រទេសទាំងអស់តម្រូវឱ្យប្រជាជនមានចូលរួមក្នុងការប្រមូលពន្ធ និងបង់ពន្ធជូនទៅរដ្ឋាភិបាលទាំងអស់ ដើម្បីប្រមូលយកនូវថវិការមកជួយទ្រទ្រង់ និងអភិវឌ្ឍន៍ដល់សេដ្ឋកិច្ចរបស់ប្រទេសរៀងៗខ្លួន។ ប្រទេសកម្ពុជាយើងក៏បានដាក់នៅផែនការដើម្បីឱ្យប្រជាជនមានការចូលក្នុងការបង់ពន្ធជូនទៅអគ្គនាយកដ្ឋានពន្ធដារ។ នៅក្នុងនោះដែលអគ្គនាយកដ្ឋានពន្ធដារ បានដាក់នៅនីតិវិធីក្នុងការបង្ការហានិភ័យនៅពេលប្រមូលពន្ធដូចខាងក្រោមនេះ៖

- ត្រូវមានការដាក់ទោសទណ្ឌនឹងមានពិន័យជាប្រាក់ទៅតាមផ្លូវច្បាប់នៅក្នុងប្រទេស ចំពោះជនណាដែលគេចវេះមិនព្រមបង់ពន្ធ
- រៀបចំវិធីសាស្រ្ត និងកសាងផែនការសម្រាប់ការប្រមូលពន្ធឱ្យមានប្រសិទ្ធិភាពខ្ពស់
- អគ្គនាយកដ្ឋានពន្ធដារ រិះរកគ្រប់វិធីពន្យល់ណែនាំប្រជាជនឱ្យយល់ដឹងពីការបង់ពន្ធ
- មានការសម្របសម្រួលនិងផ្លាស់ប្តូរព័ត៌មានទិន្នន័យកិច្ចព្រមព្រៀងអន្តរជាតិស្តីពីពន្ធដារសហប្រតិបត្តិការ និងវេទិកានានា ស្តីពីការបង់ពន្ធនៅកម្ពុជា
- កត់ត្រា រក្សា ពិនិត្យ និងតាមដានសំណើសុំពន្ធដារពីការប្រមូលពន្ធ
- សហការ និងចូលរួមក្នុងការងារនានាពាក់ព័ន្ធនឹងវិស័យការប្រការមូលពន្ធ
- សម្របសម្រួល និងសហការជាមួយនាយកដ្ឋានអង្គភាព ឬស្ថាប័ននានាទាក់ទិននឹងការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធាន នាយកដ្ឋានពន្ធដារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជា
- ក្នុងការបំពេញភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងនាយកដ្ឋានអគ្គនាយឱវាទ អគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារ អន្តរជាតិត្រូវសហការជាមួយប្រធាននាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នា។

### ង. ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

- ❖ ការដោះស្រាយវិវាទពន្ធដារសំដៅដល់ការដោះស្រាយបណ្តឹងតវ៉ារបស់ពន្ធ។ ក្នុងករណីដែលអ្នកជាប់ពន្ធមិនសុខចិត្ត និងការកំណត់ពន្ធរបស់រដ្ឋបាលសារពើពន្ធទេ អ្នកជាប់ពន្ធមានសិទ្ធិតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ គណៈកម្មការសម្រុះសម្រួលសារពើពន្ធ និងតុលាការ។
- ❖ ការតវ៉ាខាងរដ្ឋបាលពុំធ្វើឲ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ។

- វិធាននៃការដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើត្រូវបានកំណត់ពន្ធ

ក. អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធឡើងវិញ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយយរដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ានាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេចឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។

ខ. ការតវ៉ាខាងរដ្ឋបាលត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដែលមានចែងនៅក្នុងមាត្រា១២១នៃច្បាប់ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ។

គ. ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទាមទារបំណុលពន្ធឡើង។

- ការតវ៉ាខាងផ្នែករដ្ឋបាលអាចទទួលនិងទទួលយកបានបើសិនជាក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោមៈ

១. លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា បើសិនជាមាន។

២. សេចក្តីយោងលើការរកកំណត់សេចក្តីសម្រេច ឬលទ្ធផលជាកម្មវត្ថុនៃពាក្យតវ៉ា។

៣. ដើមហេតុ ឬអំពើជាកម្មវត្ថុនៃពាក្យតវ៉ា។

៤. ហេតុផលនៃការតវ៉ា។

៥. កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ ឬហត្ថលេខារបស់អ្នកតំណាងមានការអនុញ្ញាត្តិរបស់អ្នកជាប់ពន្ធ បើមានភាពចាំបាច់។

-រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីប្រកាសជាថ្មីក្នុងរយៈពេល៦០ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធឬសេចក្តីសម្រេចផ្សេងៗ ដែលអ្នកជាប់ពន្ធតវ៉ា។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសម្រេចនេះ។

ប្រសិនបើអ្នកជាប់ពន្ធមិនយល់លើការសម្រេចសេចក្តីសម្រេចថ្មីនេះរបស់រដ្ឋបាលសារពើពន្ធទេ នោះអ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃ។

-ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មការសម្រុះសម្រួលសារពើពន្ធត្រូវកំណត់ដោយអនុក្រឹតតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

-អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់ គណៈកម្មការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃក្រោយពីទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។

អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅធនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់បន្ថែមពន្ធ និងការប្រាក់ផ្សេងៗដែលទាក់ទិននឹងវិវាទតាមការកំណត់រដ្ឋបាលសារពើពន្ធ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។

### ៣.២.៤ មូលដ្ឋានគិតពន្ធ អត្រាពន្ធ និងការគណនាពន្ធ

#### ក. មូលដ្ឋានគិតពន្ធ

ពន្ធកាត់ទុក ត្រូវបានគណនាលើចំនួនទឹកប្រាក់ដុលដែលត្រូវទូទាត់ឱ្យបុគ្គលណាមួយ។ ចំពោះការទូទាត់ប្រាក់ឱ្យ អនិវាសនជន ដែលទាក់ទិនដល់ការផ្គត់ផ្គង់សម្ភារៈបរិក្ខាផង និងសេវាផង ដូចជាក្នុងការទូទាត់ទិញម៉ាស៊ីនពីក្រៅប្រទេសដែលរួមមានថ្លៃទិញម៉ាស៊ីន និងថ្លៃសេវាផ្គុំដំឡើង ដោយអ្នកបច្ចេកទេសជាបុគ្គលអនិវាសនជនផ្តល់ដោយអ្នកលក់ (សម្រាប់ដំណើរការដើមដំបូងនៃម៉ាស៊ីន) មូលដ្ឋានសម្រាប់គិតពន្ធកាត់ទុក គឺជាចំណែកប្រាក់ដែលទាក់ទិននឹងចំណាយផ្គុំឡើងនេះតែប៉ុណ្ណោះ។ ដរាបណាការទូទាត់មិនចាត់ជាចំណាយ កាតព្វកិច្ចកាត់ទុកពន្ធនិងមិនកើតឡើងដែរ។ ប៉ុន្តែការទូទាត់នេះត្រូវបានចាត់ទុកថាធ្វើឡើង

ប្រសិនបើការទូទាត់នេះត្រូវបានកាត់កងជាចំណាយអាជីវកម្ម ហើយភ្នាក់ងារកាត់ត្រូវបង់ពន្ធកាត់ទុក ក្នុងនាមជាអ្នកទទួល។

**ខ. អត្រាពន្ធ**

- ពន្ធកាត់ទុកទូទៅ

*អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបើក ឬទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឱ្យដល់បុគ្គលនិវាសនជនត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម៖

១- អត្រា១៥% ចំពោះប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការ បំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល។ ប្រាក់ចំណូលនេះមានអាទិ៍៖ ប្រាក់ចំណូលពីកំរៃជើងសារ ឬ ជើងសារជំនួញ ប្រាក់ចំណូលពីសកម្មភាព ដឹកជញ្ជូន ជួសជុល សាងសង់ គ្រប់គ្រង ពិគ្រោះយោបល់ ប្រាក់ចំណូលពីសេវាប្រហាក់ប្រហែល ដូចជាសេវាបច្ចេកទេស គណនេយ្យ ការសិក្សា...។

២- អត្រា១៥% ចំពោះសួយសារ ពីទ្រព្យសកម្មអរូបី និងសួយសារ ភាគកម្ម ក្នុងធនធានរ៉ែ

- សំរាប់គោលដៅនៃពន្ធកាត់ទុក សួយសារចំពោះទ្រព្យសកម្មអរូបីសំដៅដល់ ចំណូលជាសាច់ប្រាក់ ឬជាវត្ថុដែលទាក់ទិននឹងការអនុញ្ញាតឱ្យប្រើប្រាស់នូវសិទ្ធិបោះពុម្ពផ្សាយ និងលក់ស្នាដៃអក្សរសាស្ត្រ វិទ្យាសាស្ត្រប្រកាសនីយបត្រតក្កកម្ម ម៉ាកសញ្ញាផលិតផល ម៉ាកសញ្ញាពាណិជ្ជកម្ម
- សម្រាប់គោលដៅនៃពន្ធកាត់ទុកនេះសួយសារចំពោះភាគកម្មធនធានរ៉ែសំដៅដល់អត្ថប្រយោជន៍ជាប្រាក់ ឬជាវត្ថុដែលទទួលបានទាក់ទិន និងភាគកម្មនេះ។
- អត្រា១៥% ចំពោះការប្រាក់ដែលអ្នកជាប់ពន្ធនិវាសជន ប្រកបអាជីវកម្មដែលមិនមែនជាអនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន។

៣- អត្រា១០% ចំពោះប្រាក់ចំណូលពីកាជួលចលនទ្រព្យ ឬ អចលនទ្រព្យ។ សម្រាប់គោលដៅនៃពន្ធកាត់ទុក ប្រាក់ចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យគឺសំដៅដល់សាច់ប្រាក់ ឬវត្ថុដែលអ្នកជួលបានបង់សម្រាប់ជាថ្លូវនៃការប្រើប្រាស់ចលនទ្រព្យ ដូចជា បរិក្ខារឧស្សាហកម្ម គ្រឿងចក្រ រថយន្ត... អចនទ្រព្យដូចជា ដីធ្លី ផ្ទះសំបែង សំណង់ ផ្សេងៗ...

៤- អត្រា៦% ចំពោះការប្រាក់ ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមាន គណនីបញ្ញើមានការកំណត់(Fixed Account Deposit)។

៥- អត្រា៤% ចំពោះការប្រាក់ដែលធនាគារ ឬ ស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមាន ប្រាក់បញ្ញើនៅក្នុងគណនីសន្សំគ្មានកាលកំណត់ (Saving Account Deposit) ។

*អត្រា១៤% ចំពោះការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាដូចជាមានចែងក្នុងមាត្រា ៣៣ថ្មីនៃ ច្បាប់ស្តីពីសារពើពន្ធ ឱ្យអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវសាច់ប្រាក់ពន្ធ ១៤%នៃទឹកប្រាក់ត្រូវបង់។

ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្ត លើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅកម្ពុជា។ ដោយមិនមានការកម្រិតត្រឹមត្រូវតែ ប្រាក់ចំណូលលដូចខាងក្រោមនេះប្រាក់ចំណូលប្រភពកម្ពុជារួមមាន៖

ក. ការប្រាក់ ដែលបងដោយសារសេហគ្រាសនិវានសជនឬ ក្រុមអាជីវកម្ម និងនិវាសនជនឬស្ថាប័នរបស់រដ្ឋាភិបាលនៃកម្ពុជា។

ខ. ភាគលាភ ដែលបានបែងចែកដោយសហគ្រាសនិវាសនជន

គ. ប្រាក់ចំណូលពី សេវាកម្មដែលបានបំពេញនៅកម្ពុជា

ឃ.ប្រាក់ចំណូលពី ការគ្រប់គ្រង់និងសេវាបច្ចេកទេស ដេលបានទូទាត់ដោបុគ្គលនិវាសជន។

ង. ប្រាក់ចំណូលដែលបានមកពី ចលនទ្រព្យឬអចលនទ្រព្យ ក្នុងករណីដែល ទ្រព្យនោះស្ថិតនៅក្នុងកម្ពុជា

ច.ប្រាក់សួយសារ ដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបី ដែលបានទូទាត់ដោយបុគ្គលនិវាសនជនឬបុគ្គលអនិវាសនជន តាមរយៈគ្រិះស្ថានអចិន្ត្រយ៍ដែលបានតាំងនៅកម្ពុជា

ឆ. ផលចំណេញពីការលក់អចលនទ្រព្យ ដែលស្ថិតនៅក្នុងកកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍

- ពន្ធកាត់ទុកជាពន្ធចុងក្រោយ

ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់បុគ្គលនិវាសនជនមិនស្ថិតក្រោមរបបស្វ័យប្រកាសតាមមាត្រា២៥នៃច្បាប់នេះ និងពន្ធកាត់ទុកលើទូទាត់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជនតាមមាត្រា២៦នៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ ឬការបែងចែកដែលមានបញ្ជាក់ក្នុងមាត្រាទាំងឡាយនៃច្បាប់នេះ។

**គ. ការគណនាពន្ធ**

ពន្ធកាត់ទុក ត្រូវបានគណនាដោយការគុណមូលដ្ឋានគិតពន្ធនឹងអត្រាពន្ធដែលអនុវត្ត។

( ពន្ធកាត់ទុក =ប្រាក់មូលដ្ឋានគិតពន្ធ x អត្រាពន្ធ )

ឧទាហរណ៍ទី១៖ លោកB ជានិវាសនជនជាងជួសជុលម៉ាស៊ីនត្រជាក់ ហើយថ្ងៃមួយក្រុមហ៊ុន Tiger បានហៅគាត់ឱ្យមកជួសជុលម៉ាស៊ីនត្រជាក់។ ក្រោយពេលបំពេញការងាររួចគាត់ក៏ទទួលបានប្រាក់ឈ្នួល៣០០$។ ចូរគណនាពន្ធកាត់ទុកដែលក្រុមហ៊ុនបានកាត់ពីលោកB។

មូលដ្ឋានគិតពន្ធ=៣០០$ x ១៥% = ៤៥$

ដូចនេះ ប្រាក់ពន្ធដែលក្រុមហ៊ុនកាត់ពីលោកBនោះគឺ ៤៥$

ឧទាហរណ៍ទី២៖ ក្រុមហ៊ុន ABC បានបង់ចំណាយថ្លៃជួលផ្ទះឱ្យទៅលោក C ចំនួន២,០០០$ ។ ចូរគណនាពន្ធកាត់ទុកដែលក្រុមហ៊ុន ABC ត្រូវកាត់ទុកពីលោកC។

មូលដ្ឋានគិតពន្ធ=២,០០០$ x ១០% = ២០០$

ដូចនេះ ប្រាក់ពន្ធដែលក្រុមហ៊ុនABC កាត់ពីលោកCនោះគឺ ២០០$

**៣.២.៥ សិទ្ធអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលពន្ធ**

អនុលោមតាមមាត្រា១៩៤នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានអំណាចដូចខាងក្រោម៖

ក. កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២០៩និងមាត្រា២១០ នៃច្បាប់ស្តីពីសារពើពន្ធ។

ខ. តម្រូវឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួនដូចចែងក្នុងមាត្រា២០២ នៃច្បាប់ស្តីពីសារពើពន្ធ។

គ. កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុកនិងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ២០១ និងមាត្រា២៣០ នៃច្បាប់ស្តីពីសារពើពន្ធ។

ឃ. ទាមទារឲ្យអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានទាក់ទិនអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០២នៃច្បាប់ស្តីពីសារពើពន្ធ។

ង. ចូលលំនៅឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២៣០នៃច្បាប់ស្តីពីសារពើពន្ធ។

ច. ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពី ឬដែលទាក់ទិននិងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា២០៩ នៃច្បាប់ស្តីពីសារពើពន្ធ។

### ៣.៣.៥ ការអនុវត្តពន្ធកាត់ទុកក្នុងករណីដែលមានកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា

ក្នុងករណីអ្នកជាប់ពន្ធដែលស្ថិតក្នុងប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការចៀងវាងការយកពន្ធត្រួតគ្នា និងមានវិញ្ញាបនបត្រដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តកាតព្វកិច្ចពន្ធកាត់ទុកផ្អែកតាមកិច្ចព្រមព្រៀងនៃប្រទេសនីមួយៗ។ កិច្ចព្រមព្រៀងការលុបបំបាតការយកពន្ធត្រួតគ្នា រវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយបណ្តាលប្រទេសនានា និងការផ្តល់អត្ថប្រយោជន៍ដល់ភាគីចុះហត្ថលេខាលើកិច្ចការពង្រីកកិច្ចសហប្រត្តិបត្តិការទ្វេភាគី ធ្វើឱ្យប្រាកដប្រជាក្នុងការកំណត់សិទ្ធិនៃការយកពន្ធ កំណើនមូលដ្ឋានគិតពន្ធ តាមរយៈការទាក់ទាញវិនិយោគដោយផ្ទាល់។ មិនត្រឹមតែប៉ុណ្ណោះ លំហូរមូលធន ការផ្ទេរបច្ចេកទេសវិទ្យា និងជំនាញពីបរទេស ការការពានិវាសនជន ពីការប្រព្រឹត្តិកម្មមិនត្រឹមត្រូវពាក់ពន្ធ និងការការពារចំណូលពន្ធក្នុងស្រុក តាមរយៈកិច្ចសហប្រត្តិការការប្រយុទ្ធប្រឆាំងនឹងការគេចវេសពន្ធរវាងប្រទេសនឹងប្រទេសដែលត្រូវបានចុះហត្ថលេខាជាមួយគ្នា។

យោងតាមអគ្គនាយកដ្ឋានពន្ធដារកម្ពុជាបានបញ្ជាក់ថា ដើម្បីជួយសម្រួលក្នុងការអនុវត្តន៍ពន្ធកាត់ទុកក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធ ពាក់ព័ន្ធនិងពន្ធកាត់ទុកត្រូវធ្វើតាមការណែនាំដូចខាងក្រោម

- អ្នកជាប់ពន្ធនិវាសនជនកម្ពុជា ត្រូវអនុវត្តតាមវិធីគណនេយ្យអន្តរជាតិ នៃកម្ពុជាលើរាល់ការទូរទាត់ចំណូលជាភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ទៅអ្នកជាប់ពន្ធនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ ការទូទាត់ចំណូលខាងលើត្រូវចាត់ទុកថាបានទូទាត់ប្រសិនបើបានកត់ត្រាក្នុងបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធនិវាសនជនលកម្ពុជា ដែលជាភ្នាក់ងារកាត់ទុក។
- តាមមាត្រាស្តីពីការចូលជាធរមាននៃ DTA ពន្ធកាត់ទុកលើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ត្រូវមានប្រសិទ្ធិភាពអនុវត្តនៅប្រទេសប្រភព នៅពេលដែលប្រាក់ចំណូលកើតឡើងនៅថ្ងៃទីមួយនៃខែមករាឬថ្ងៃបន្ទាប់ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។
- សម្រាប់គោលដៅនៃពន្ធកាត់ទុក លើកការបែងចែងភាគលាភ ប្រាក់ចំណូលកើតឡើងខាងលើ គឺជាប្រាក់ចំណូលដែលអ្នកជាប់ពន្ធនិវាសនជន បានទូរទាត់នៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។
- ការទូទាត់ចំណូលជាភាគលាភ ការប្រាក់សួយសារ និងកម្រៃសេវាបច្ចេកទេស ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា២៦ថ្មី (មួយ) នៃច្បាប់ស្តីពីបន្ធ នៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនឱ្យលើសពីអត្រាកំណត់នៅក្នុង DTA ដូចមានចែងក្នុងសេចក្តីណែនាំលេខ ៤០៨៦ អពដ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពី ការជៀងវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធ ពាក់ពន្ធនឹងពន្ធលើប្រាក់ចំណូល។

### ៣.២.៧ ភាតព្វកិច្ចដាក់លិខិតប្រកាស ការបង់ប្រាក់ពន្ធ និងទោសទណ្ឌ

#### ក. ការដាក់លិខិតប្រកាស

- ការប្រកាសពន្ធ

លិខិតប្រកាសពន្ធត្រូវដាក់ទៅការិយាល័យអ្នកជាប់ពន្ធធំ( សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សាខាក្រុមហ៊ុនបរទេស ឬក្រុមហ៊ុនពហុជាតិ ឬសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១០០០លានរៀលឡើង) ឬសាខាពន្ធដារខេត្ត ខណ្ឌដែលមានអាជីវកម្មនោះតាំងនៅ (សម្រាប់អ្នកជាប់ពន្ធដទៃ)។ ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុត១៥ថ្ងៃនៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។ ភ្នាក់ងារកាត់ទុកសំដៅដល់បុគ្គល ឬនីតិបុគ្គលដែលបទបញ្ញត្តិស្ដីពីពន្ធដារ បានតម្រូវឱ្យធ្វើការកាត់ទុក និងបង់ពន្ធចូលថវិការរដ្ឋក្នុងនាមអ្នកទទួល។

- ការដាក់លិខិតប្រកាសសារពើពន្ធ

ការដាក់លិខិតប្រកាសសារពើពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១. អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ ពេលវេលា និងកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២. លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។

៣. អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ឬអ្នកវិនិយោគទាំងអស់ អាចដាក់លិខិតប្រកាសសារពើពន្ធតាមប្រព័ន្ធទទួលលិខិតប្រកាសអេឡិចត្រូនិករបស់រដ្ឋបាលសារពើពន្ធ ហើយមានតម្លៃស្មើគ្នានឹងលិខិតប្រកាសសារពើពន្ធជាលាយលក្ខណ៍អក្សរដែលជាច្បាប់ដើម។

#### ខ. ការបង់ប្រាក់ពន្ធ

យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុកនិងត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់តាមប្រពន្ធអនឡាញ E-Filing។

- **ការធ្វេសប្រហែស**

  អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្ដីពីពន្ធដារមិនលើសពី ១០(ដប់)ភាគរយ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់។

- **ការធ្វេសប្រហែសធ្ងន់ធ្ងរ**

  អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនជាងតិចប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្ដីពីពន្ធដារលើសពី ១០(ដប់)ភាគរយ។

#### ខ. ទោសទណ្ឌ

ភ្នាក់ងារកាត់ទុកត្រូវទទួលខុសត្រូវយ៉ាងពេញលេញ និងរួមគ្នាជាមួយនឹងបុគ្គជាមុខសញ្ញា គ្រកាត់ទុកប្រាក់ចំពោះពន្ធដែលត្រូវកាត់ទុក និងបង់ជូនរដ្ឋបាលសារពើពន្ធ។ ក្នុងករណីដែលភ្នាក់ងារកាត់ទុកមិនបាន

បង់ឱ្យបានត្រឹមត្រូវនូវប្រាក់ពន្ធដែលច្បាប់បានតម្រូវឱ្យខ្លួនធ្វើការកាត់ទុក និងបង់ជូនទៅឱ្យរដ្ឋបាលសារពន្ធ ភ្នាក់ងារកាត់ទុកនឹងត្រូវទទួលរងនូវការកំណត់ពន្ធឯកតាភាគី ឬការកំណត់ពន្ធឡើងវិញព្រមទាំងប្រាក់ពិន័យផ្សេងទៀតដូចគ្នានឹងបំណុលរបស់ភ្នាក់ងារកាត់ទុកខ្លួនឯងផ្ទាល់ផងដែរ។ ភ្នាក់ងារកាត់ទុកក៏ត្រូវទទួលរងនូវទោសទណ្ឌផ្សេងៗទៀតដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

➢ **ការត្រួតពិនិត្យលើចំណុចខ្វះខាតពេលបង់ពន្ធ**

អគ្គនាយកដ្ឋានពន្ធដារបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានទស្សនវិស័យជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្ត លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ តែក៏នៅមានចំណុចខ្វះខាតក្នុងអំឡុងពេលបង់ពន្ធដូចខាងក្រោមៈ

- កើតមានអំពើពុករលួយ បក្សពួកនិយម
- ការខកខានមិនបានបង់ពន្ធតាមការកំណត់
- ការរៀបចំគោលនយោបាយសារពើពន្ធមួយចំនួននៅមិនទាន់ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- ការរៀបចំសេចក្តីព្រាងច្បាប់ មិនទាន់ស្របតាមលិខិតបទដ្ឋានស្តីពីពន្ធដារ កំណត់បញ្ជីឯកសារ និងលិខិតយុត្តិការនានា
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិនៅមានចន្លោះប្រហោង
- ការផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធមិនទាន់បានល្អក្នុងការផ្តល់សេវានិងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

➢ **អំពើពុករលួយក្នុងប្រព័ន្ធពន្ធដារ**

អ្នកឆ្លើយតបការស្ទង់មតិមួយចំនួនទទួលស្គាល់ថា នៅមានអំពើពុករលួយក្នុងប្រព័ន្ធដារ ប៉ុន្តែក៏ពិបាកកំណត់ នឹងសឹងតែមិនអាចរកឃើញបាន ពីព្រោះថាការស៊ីគ្រលំគ្នារវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារកើតជាសម្ងាត់។ បន្ថែមពីលើនេះ មានកត្តាដទៃទៀត ដែលជម្រុញឱ្យមានអំពើពុករលួយរួមទាំងភាពស្មុកស្មាញនៃច្បាប់សារពើពន្ធតួនាទីដ៏មានបុព្វសិទ្ធិរបស់មន្ត្រីពន្ធដារ និងទម្លាប់ក្នុងការចំណាយក្រៅផ្លូវការ និងបរិយាកាសទូទៅនៃវិស័យសាធារណៈ។ កត្តាទាំងនេះ បានរួមចំណែកក្នុងការបង្កើតវប្បធម៌ពុករលួយដែលកំពុងតែមានក្នុងប្រព័ន្ធដារ។

## ៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធកាត់ទុកចំពោះសេដ្ឋកិច្ចជាតិ និងផលប៉ះពាល់ចំពោះអ្នកជាប់ពន្ធ

### ៣.៣.១ ផលប្រយោជន៍ក្នុងការប្រមូលពន្ធកាត់ទុកចំពោះសេដ្ឋកិច្ចជាតិ




REGISTRATION TAX COLLECTION IN CAMBODIA

ពន្ធ គឺជាចំណូលជាតិមួយយ៉ាងសំខាន់ ដែលអាចចូលរួមដោះស្រាយបញ្ហាសេដ្ឋកិច្ចជាតិជាមួយរដ្ឋាភិបាល ក៏ដូចជាការអភិវឌ្ឍសង្គមជាតិបានយ៉ាងច្រើន។ ចំណូលមួយភាគធំរបស់ជាតិ គឺបានមកពីការប្រមូលពន្ធក្នុងវិស័យពន្ធដារកម្ពុជា។ ហើយការប្រមូលពន្ធកាត់ទុកបានផ្ដល់ប្រយោជន៍ចំពោះខ្លួនឯង និងសង្គមជាតិដូចជា ៖

- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រី កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និង និវត្តន៍ជន ។
- ពន្ធជាប្រភពចំណូលដ៏សំខាន់ដើម្បីទ្រទ្រង់ និង ដំណើរការរដ្ឋទាំងមូល ៖ ពន្ធដែលប្រមូលបានគឺសម្រាប់ចំណាយទៅលើ គ្រឿងឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យនៅតាមក្រសួង មន្ទីរស្ថាប័ន និងអង្គភាពចំណុះឱ្យរដ្ឋ ។
- ប្រាក់ពន្ធដែលប្រមូលបាន គឺសម្រាប់ចំណាយ ទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គមដូចជា ៖ ផ្លូវថ្នល់ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម ។
- ចំណាយទៅលើវិស័យអប់រំ និងសុខាភិបាល ៖ ការសិក្សា អប់រំចំណេះដឹងទូទៅដោយមិនបង់ប្រាក់ ការព្យាបាលនៅតាមមណ្ឌលសុខភាព និង មន្ទីរពេទ្យរដ្ឋ
- ប្រាក់ពន្ធក៏ត្រូវបានចំណាយទៅលើវិស័យសន្តិសុខ សណ្ដាប់ធ្នាប់សង្គម និងវិស័យការពារជាតិ
- ការបង់ពន្ធគឺជាការទទួលខុសត្រូវសង្គម និងបង្ហាញពីកាយវិការស្របច្បាប់របស់រដ្ឋ ។




❖ **ការជកហូតពន្ធ គឺដើម្បី៖**

- ទ្រទ្រង់ ឬបំពេញឱ្យការចំណាយ ដូចជា ប្រាក់ខែ ចំណាយសម្ភារៈការិយាល័យ ចំណាយបេសកកម្ម
- ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ ការថែទាំ សុខភាព និងការអភិវឌ្ឍ
- ទ្រទ្រង់សេវាសាធារណៈដូចជា ការការពារជាតិ ធានារ៉ាប់រងសង្គម
- ឱ្យប្រជាពលរដ្ឋបានបំពេញកាតព្វកិច្ច ជាពលរដ្ឋល្អ ទទួលខុសត្រូវចំពោះជាតិ
- ឱ្យរដ្ឋមានចំណូល និងថវិកាគ្រប់គ្រាន់ សម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ
- រារាំង ឬទប់ស្កាត់ វិស័យសេដ្ឋកិច្ចណាមួយដែលរដ្ឋចង់ទប់ស្កាត់
- ឱ្យទំនិញ និងសេវាទាំងឡាយប្រកួតប្រជែងដោយសេរី និងមានតម្លាភាព។

❖ **ដើម្បីឱ្យចំណូលពន្ធកើនឡើងរដ្ឋត្រូវ៖**

- ពង្រឹងសមត្ថភាពប្រមូលពន្ធ(លុបបំបាត់ការកិបកេងរវាងមន្ត្រីពន្ធដារ ភ្នាក់ងារពន្ធដារ និងអ្នកជាប់ពន្ធ) គឺប្រមូលពន្ធឱ្យបានត្រឹមត្រូវ ពង្រីកមូលដ្ឋានយកពន្ធ(កំណត់មូលដ្ឋានថ្មីដែលជាប់ពន្ធ)
- បង្កើនអត្រាពន្ធ (លើទំនិញ និងសេវាមួយចំនួន)
- បង្កើតប្រភេទពន្ធថ្មី (ដែលមិនទាន់មាន ឬនៅខ្វះចន្លោះ)។

❖ **ផលវិជ្ជមានពីការយកពន្ធរបស់រដ្ឋ លើបុគ្គលម្នាក់ៗ អង្គការ និងក្រុមហ៊ុនមានដូចជា៖**

- ការយកពន្ធធ្វើអ្នកជាប់ពន្ធបានបំពេញកាតព្វកិច្ច ក្នុងការអភិវឌ្ឍប្រទេសជាតិ ហើយមានអារម្មណ៍ថាខ្លួនឯងជាផ្នែកមួយរបស់ប្រទេស និងមានការទទួលខុសត្រូវចំពោះប្រទេសជាតិ
- ថវិកាដែលបានពីការយកពន្ធ គឺជាប្រភពចំណូលដ៏សំខាន់នៃថវិការដ្ឋ ហើយអាចប្រើប្រាស់ថវិកាទាំងនេះដើម្បីអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើន និងទ្រទ្រង់ដល់សេវាសាធារណៈ
- ថវិកាដែលបានមកពីការយកពន្ធ រដ្ឋអាចយកទៅកសាងហេដ្ឋារចនាសម្ព័ន្ធដូចជា៖ ផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន ដែលមានផលប្រយោជន៍សម្រាប់សង្គមជាតិ

- ការយកពន្ធជួយទ្រទ្រង់ស្ថេរភាពសេដ្ឋកិច្ច និងកាត់បន្ថយអសមត្ថភាពក្នុងការបែងចែកធនធាននៅក្នុងសង្គម
- ការយកពន្ធ គឺជាការលើកទឹកចិត្ត ឬបង្អាក់ទឹកចិត្តវិស័យសេដ្ឋកិច្ចណាមួយដែលរដ្ឋចង់ទប់ស្កាត់។

**៣.៣.២ ការប្រមូលពន្ធកាត់ទុកផ្តល់ផលប៉ះពាល់ដល់អ្នកជាប់ពន្ធ**

- ការយកពន្ធ អាចជាឧបសគ្គក្នុងការទាក់ទាញ ឬរារាំការវិនិយោគ ឬការធ្វើអាជីវកម្ម ផលិតកម្ម ឬសេវាកម្មផ្សេងៗ
- ការយកពន្ធ អាចប៉ះពាល់ដល់តម្លៃទំនិញ និងសេវា
- ការយកពន្ធ ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន
- ជាទូទៅ ទម្រង់បែបបទពន្ធមានភាពស្មុកស្មាញ និងពិបាកយល់
- ការយកពន្ធ អាចប៉ះពាល់ការវិនិយោគ និកម្មភាព និងសេដ្ឋកិច្ច
- ការយកពន្ធ អាចរាំងស្ទះដល់ការអភិវឌ្ឍន៍។

❖ **ការធ្លាក់ចុះនូវសេដ្ឋកិច្ចជាតិ**

ប្រទេសកម្ពុជាយើងធ្លាប់ឆ្លងកាត់សង្គ្រាមជាច្រើនដំណាក់កាល ដែលជាហេតុនាំឱ្យសេដ្ឋកិច្ចប្រទេសជាតិមានការធ្លាក់ចុះជាខ្លាំង ជាពិសេសនោះក្នុងកំឡុងឆ្នាំ ១៩៧៥-១៩៧៩ ប្រទេសកម្ពុជារងនូវវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរបំផុត ដោយសាររបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ មន្ទីរពេទ្យ សាលារៀន វត្តអារាម លុបបំបាត់រូបិយវត្ថុ គ្មានសកម្មភាពសេដ្ឋកិច្ច គ្មានការប្រមូលពន្ធ ប្រជាជនរស់នៅរួម ធ្វើការរួម ហូបចុករួម។ ក្រោយរំដោះថ្ងៃ ៧ កមរា ឆ្នាំ១៩៧៩ អ្វីៗនៅកម្ពុជាត្រូវបានចាប់ផ្តើមឡើងវិញពីចំណុចសូន្យទៅ ហើយយើងសង្កេតឃើញថាមានការចាប់ផ្តើមរីកចម្រើនស្ទើរគ្រប់វិស័យ សកម្មភាពសេដ្ឋកិច្ចលូតលាស់ឡើងវិញគួរឱ្យកត់សម្គាល់។ ជាអកុសល មកដល់ឆ្នាំ ២០១៩ កន្លងផុតទៅថ្មីៗនេះ ប្រទេសកម្ពុជាក៏រងនូវវិបត្តិសេដ្ឋកិច្ចម្តងទៀត ដោយសារជម្ងឺដ៏កាចសាហាវមួយ មានឈ្មោះថា ជម្ងឺកូវីត១៩ ដែលបានរាតត្បាតពាសពេញប្រទេស និងប្រទេសមួយចំនួនធំទៀតលើពិភពលោក ធ្វើឱ្យប្រទេសជាតិទាំងមូលត្រូវផ្អាកនូវសកម្មភាពសេដ្ឋកិច្ច មានការបិទខ្ទប់ គ្មានចំណូលចូលថវិការដ្ឋ ជាហេតុធ្វើឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងសង្គមជាតិយ៉ាងខ្លាំង។ នាបច្ចុប្បន្ននេះ សេដ្ឋកិច្ចនៅប្រទេសកម្ពុជាបានងើបឡើងវិញក្នុងស្ថានភាពមួយមានកម្រិត ដោយការរីចចម្រើនស្ទើរគ្រប់វិស័យ ជាពិសេសវិស័យពន្ធដារនៅកម្ពុជា។ ទោះជាយ៉ាងណាក៏ ដើម្បីឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែមានសក្តានុពល រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ចំពោះ៖

- សិទ្ធិទទួលបានការអប់រំ ត្រូវតែបានការពារក្នុងករណីមានការបិទសាលារៀន ឧទាហរណ៍ ប្រសិនជាអាចធ្វើទៅបាន សិក្សាតាមកម្មវិធីតាមអនឡាញ និងការចាក់ផ្សាយតាមទូរទស្សន៍ និងវិទ្យុឯកទេស។ ក្មេងស្រីអាចនឹងទទួលរងផលប៉ះពាល់ដោយមិនសមាមាត្រ ដោយហេតុថាមនុស្សជាច្រើនប្រឈមស្រាប់ហើយនូវឧបសគ្គធំៗក្នុងការទៅសាលារៀន ហើយបច្ចុប្បន្ននេះ គេរំពឹងថានឹងទទួលបានកាន់តែច្រើនឡើងថែមទៀតនូវការងារនៅផ្ទះ។ ឱកាសអប់រំមានកំណត់សម្រាប់ អ្នកដែលមិនមានលទ្ធភាពប្រើអ៊ិនធឺណិត និងឧបករណ៍រៀនពីចម្ងាយផ្សេងទៀត ដែលប្រឈមខ្លាំងថែមទៀតទៅនឹងវិសមភាព និងភាពក្រីក្រ។ កុមារី និងកុមារា អាចបាត់បង់លទ្ធភាពទទួលបានអាហាររូបត្ថម្ភ និងសេវា

ផ្សេងៗទៀត ដែលសាលារៀនផ្តល់ឱ្យជារឿយៗ ដូចជា សុខភាពផ្លូវចិត្ត និងការអប់រំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

- គម្រោងគាំពារសង្គម គួរតែយកចិត្តទុកដាក់ជាពិសេសចំពោះកុមារ ដោយសារតែពួកគេប្រឈមនឹងភាព ងាយរងគ្រោះខ្ពស់ ដោយផ្អែកលើដំណាក់កាលដំបូងរបស់ពួកគេ នៃការអភិវឌ្ឍរាងកាយ បញ្ញាស្មារតី និងអារម្មណ៍។ ការអនុវត្តល្អបំផុត រួមមាន ការផ្ទេរសាច់ប្រាក់ទៅគ្រួសារទាំងឡាយដែលមានកូន ដែល មានប្រសិទ្ធភាពក្នុងការការពារសិទ្ធិរបស់កុមារ។
- ការអនុវត្តល្អរបស់រដ្ឋាភិបាលនានា វិស័យសាធារណៈ និងវិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដើម្បីកាត់បន្ថយទាំងផលប៉ះពាល់សេដ្ឋកិច្ចសង្គមអវិជ្ជមាននៃវិបត្តិនេះ។
- សុខភាព និងសុវត្ថិភាពការងាររបស់អ្នកដែលធ្វើការក្នុងអំឡុងពេលមានវិបត្តិនេះ ជាពិសេសបុគ្គលិកសុខាភិបាល និងបុគ្គលិកគាំទ្រ ដែលភាគច្រើនជាស្ត្រី គួរតែត្រូវបានគេវាយតម្លៃ និងដោះស្រាយ។ បុគ្គលិកសុខាភិបាល និងអ្នកផ្សេងទៀត ដែលធ្វើការក្នុងបរិស្ថានប្រឈមនឹងហានិភ័យ គួរតែត្រូវបានផ្តល់ជូននូវឧបករណ៍ការពារផ្ទាល់ខ្លួនដែលមានគុណភាព តាមតម្រូវការ។ គ្មាននរណាម្នាក់ គួរមានអារម្មណ៍បង្ខំឱ្យធ្វើការក្នុងលក្ខខណ្ឌដែលមិនចាំបាច់ ធ្វើឱ្យគ្រោះថ្នាក់ដល់សុខភាពរបស់ពួកគេឡើយ ព្រោះពួកគេខ្លាចបាត់បង់ការងារ ឬប្រាក់ខែ។
- ការជម្រុញសារពើពន្ធ និងកញ្ចប់គាំពារសង្គម ដែលមានគោលដៅផ្ទាល់ចំពោះអ្នកដែលអាចលទ្ធភាពតិចតួចបំផុតគឺចាំបាច់ដើម្បីកាត់បន្ថយផលវិបាកដ៏ធ្ងន់ធ្ងរនៃជំងឺរាតត្បាត។ វិធានការបន្ទាន់ជួយសង្គ្រោះ សេដ្ឋកិច្ច ដូចជាការឈប់សម្រាកឈឺដែលធានារក្សាប្រាក់ឈ្នួល អត្ថប្រយោជន៍នៅរក្សាឱ្យមាននៅក្នុង អំឡុងពេលឥតការងារធ្វើ ការចែកចាយស្បៀងអាហារ ការថែទាំកុមារ និងប្រាក់ចំណូលសកលជាមូល ដ្ឋាន អាចជួយធានាការពារទប់ទល់នឹងផលប៉ះពាល់ធ្ងន់ធ្ងរនៃវិបត្តិ។

**៣.៣.៣ វិបត្តិសេដ្ឋកិច្ចពិភពលោក**

ត្រឹមរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ពិភពលោកបានប្រឈមនូវវិបត្តិយ៉ាងច្រើនជាបន្តបន្ទាប់ និងដំណាលគ្នា។ វិបត្តិជំងឺកូវីដ១៩ វិបត្តិសង្គ្រាមឈ្លានពានរបស់រុស្ស៊ីលើប្រទេសអ៊ុយក្រែន វិបត្តិនៃការកើនឡើងតម្លៃថាមពល វិបត្តិស្បៀងអាហារពិភពលោក និងវិបត្តិនៃការកើនឡើងភាពក្រីក្រសកល។ នេះគេនៅមិនទាន់រាប់បញ្ចូលវិបត្តិសកលដ៏ធំបំផុតនៃការប្រែប្រួលអាកាសធាតុ។

❖ វិបត្តិជំងឺកូវីដ១៩

ត្រឹមរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ពិភពលោកបានប្រឈមនូវវិបត្តិយ៉ាងច្រើនបន្តបន្ទាប់គ្នា និងដំណាលគ្នា។ ជំងឺរាតត្បាតកូវីដ១៩ត្រូវបានកំណត់អត្តសញ្ញាណដំបូង នៅទីក្រុងវូហាន ប្រទេសចិន ក្នុងខែធ្នូ ឆ្នាំ២០១៩។ ជំងឺនេះបានរីករាលដាលទៅកាន់ពិភពលោកទាំងមូល។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ ជំងឺនេះបានបណ្តាលឱ្យមានអ្នកឆ្លងជាង៦រយលាន៥៦ម៉ឺននាក់ និងមានអ្នកស្លាប់ចំនួនជាង៦,៧លាននាក់ ដែលធ្វើឱ្យជំងឺនេះក្លាយជាវិបត្តិជំងឺមួយក្នុងចំណោមវិបត្តិជំងឺដែលធ្វើឱ្យមនុស្សស្លាប់ច្រើនបំផុតក្នុងប្រវត្តិសាស្ត្រ។

ជំងឺនេះបង្កឱ្យមានវិបត្តិធ្ងន់ធ្ងរដល់សង្គម និងសេដ្ឋកិច្ចនៅជុំវិញពិភពលោក។ វាជាវិបត្តិសេដ្ឋកិច្ចសកលដ៏ធំបំផុតចាប់តាំងពីវិបត្តិសេដ្ឋកិច្ចឆ្នាំ១៩២៩។ ពិភពលោកត្រូវប្រឈមកង្វះខាតការផ្គត់ផ្គង់សកល រួមទាំងការខ្វះខាតស្បៀងអាហារ។ ការបិទប្រទេសក្នុងកម្រិតទ្រង់ទ្រាយធំ និងជាកម្រិតសកលមិនធ្លាប់មានត្រូវកើតឡើង។

វិបត្តិក៏បង្កផលប៉ះពាល់ដល់ការបិទសាលារៀន ការផ្សព្វផ្សាយព័ត៌មានមិនពិត វិបត្តិនយោបាយ បញ្ហានៃការរើសអើងពូជសាសន៍ និងវិបត្តិតុល្យភាពរវាងតម្រូវការសុខភាពសាធារណៈ និងសិទ្ធិបុគ្គល។

❖ វិបត្តិសង្គ្រាមឈ្លានពានរបស់រុស្ស៊ីលើប្រទេសអ៊ុយក្រែន

